ខែសីហា
២០២៤



# "បញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វដែលប៉ះពាល់ដល់សហគ្រិនស្ត្រី ខ្នាតតូច និងមធ្យម (MSMEs) ក្នុងការទទួលបានផលិតផលហិរញ្ញវត្ថុ សេវាកម្ម និងការវិនិយោគជាបន្តបន្ទាប់”


In partnership with Canada
ASPEN NETWORK OF DEVELOPMENT ENTREPRENEURS
ARISE
GADC Gender and Development for Cambodia
iDE Powering entrepreneurs to end poverty.
SHE powered by iDE

# មាតិកា


សង្ខេបការស្រាវជ្រាវ 3

សេចក្តីថ្លែងអំណរគុណ 4

I. សេចក្តីផ្តើម 5

1.1 ការសិក្សាស្រាវជ្រាវលើឯកសារផ្សេងៗ 5

1.1.1 តួនាទីរបស់ស្ថាប័នហិរញ្ញវត្ថុ 6

1.1.2 បទដ្ឋានសង្គម-វប្បធម៌ និងសិទ្ធិសេដ្ឋកិច្ចសង្គម 9

1.1.3 ជាតិសាសន៍ និងពូជសាសន៍ 10

1.1.4 ស្ថានភាពសមត្ថភាព 11

1.1.5 ការអប់រំ 12

1.1.6 ទំនោរផ្លូវភេទ និងការបង្ហាញអត្តសញ្ញាណយេនឌ័រចម្រុះ 13

1.1.7 ការគាំទ្របទប្បញ្ញត្តិ 13

1.1.8 ឥទ្ធិពលលើការវិនិយោគជាបន្តបន្ទាប់ 14

1.2 សេចក្តីសង្ខេបនៃការពិនិត្យឯកសារផ្សេងៗ 15

II. វិធីសាស្ត្រស្រាវជ្រាវ 16

2.1 ការប្រមូលទិន្នន័យ 17

2.2 ការវិភាគទិន្នន័យ 19

2.3 ការស្រាវជ្រាវលើសកម្មភាព 20

III. ការរកឃើញពីការស្រាវជ្រាវ 21

3.1 បញ្ហាប្រឈមទូទៅដែលប៉ះពាល់ដល់ WEs 21

3.1.1 សិទ្ធិទទួលបានព័ត៌មាន 21

3.1.2 ភាពស្មុគស្មាញនៃដំណើរការនៃការស្នើសុំកម្ចី 22

3.1.3 តម្រូវការទ្រព្យបញ្ចាំ 23

3.1.4 អត្រាការប្រាក់ខ្ពស់ 24

3.2 បញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វ 25

3.2.1 ស្ត្រីដែលមានពិការភាព 25

3.2.2 ស្ត្រីដែលចំនេះដឹងនៅមានកម្រិត 26

3.2.3 ស្ត្រីដែលមានទំនោរផ្លូវភេទ និងការបង្ហាញអត្តសញ្ញាណយេនឌ័រចម្រុះ 27

3.2.4 ស្ត្រីដែលមានសមាសភាពគ្រួសារមិនតាមប្រពៃណី 27

3.2.5 ស្ត្រីដែលគោរពសាសនាផ្សេងៗគ្នា 28

IV. យេនឌ័រនៅកន្លែងការងារ 29

ជ្រុងទី 1: សមត្ថភាពដឹងដែលមានវិចារណញ្ញាណ 29

ជ្រុងទី 2: ធនធាន 31

ជ្រុងទី 3: បទដ្ឋានក្រៅផ្លូវការ និងការអនុវត្តក្រៅប្រព័ន្ធ 32

ជ្រុងទី 4: ច្បាប់ និងគោលការណ៍ផ្លូវការ 34

V. សេចក្តីសន្និដ្ឋាន 36

ឯកសារយោង 38

ឧបសម្ព័ន្ធ

# សង្ខេបការស្រាវជ្រាវ

ការស្រាវជ្រាវសិក្សានេះស្វែងយល់ពីបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វ ដែលប៉ះពាល់ដល់សហគ្រិនស្រីខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម (MSMEs) ក្នុងការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុ និងការវិនិយោគជាបន្តបន្ទាប់ពីស្ថាប័នហិរញ្ញវត្ថុ (FIs)។ ផ្អែកលើការសិក្សាស្រាវជ្រាវមុនៗ ដែលបានសិក្សាអំពីបញ្ហាប្រឈមរបស់សហគ្រិនស្ត្រី (WEs) លើលទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុ និងទិដ្ឋភាពនៃការវិនិយោគលើសមភាពយេនឌ័រនៅក្នុងប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវនេះ នឹងពិភាក្សាបន្ថែមអំពីឧបសគ្គដែលរាំងស្ទះដល់សហគ្រិនស្ត្រី ក្នុងការទទួលបានសេវាហិរញ្ញវត្ថុតាមរយៈវិធីសាស្ត្រអន្តរប្រសព្វ ដោយស្វែងយល់ពីបទពិសោធន៍ជីវិតជាក់ស្តែងរបស់ម្ចាស់សហគ្រិនស្ត្រីខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម MSMEs ដែលមកពីស្ថានភាពផ្សេងៗគ្នា។ ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងជាមួយស្ត្រី 95 នាក់ MSMEs (2នាក់ជាLGBTQIA+, 10នាក់ជាស្ត្រីដែលមានពិការភាព) និងអ្នកផ្តល់ព័ត៌មានសំខាន់ៗចំនួន 3 នាក់ នៅភ្នំពេញ និងបាត់ដំបង រវាងប្រជាជនទីក្រុង និងជនបទ ដោយប្រើវិធីសាស្ត្រស្រាវជ្រាវបែបហ្វេមមីនីស ដែលមានសហគ្រិនស្ត្រីចំនួន 6នាក់ជាអ្នកប្រមូលទិន្នន័យ (១នាក់ជាស្ត្រីដែលមានពិការភាព)។

ការសិក្សានេះបានបង្ហាញថាបទពិសោធន៍ និងប្រវត្តិរូបផ្សេងៗគ្នានៃសហគ្រិនស្ត្រី (WEs) - រួមមានអាយុ សមត្ថភាព សមាសភាពក្នុងសង្គម សាសនា សមាសភាពគ្រួសារ និងទំនោរផ្លូវភេទ - មានឥទ្ធិពលលើការទទួលបានសេវាហិរញ្ញវត្ថុ និងការពង្រីកសកម្មភាពអាជីវកម្មរបស់ពួកគេ។ ដោយសង្កត់ធ្ងន់លើបទពិសោធន៍ជីវិតផ្សេងៗគ្នារបស់សហគ្រិនស្ត្រី ការវិភាគត្រូវបានធ្វើឡើងដោយប្រើឧបករណ៍ 'យេនឌ័រនៅកន្លែងការងារ' ដើម្បីបានផ្តល់អនុសាសន៍ល្អៗ ដែលអាចឱ្យស្ថាប័នហិរញ្ញវត្ថុបង្កើតឡើងនូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលមានលក្ខណៈបទបែន ដែលគាំទ្រដល់សហគ្រិនស្ត្រីដែលមានស្ថានភាពផ្សេងៗគ្នា (WEs) អាចអភិវឌ្ឍន៍អាជីវកម្មរបស់ពួកគេអោយក្លាយជាអាជីវកម្មដែលមានលក្ខណៈផ្លូវការ ពង្រីក និង ជះផលវិជ្ជមាននៅក្នុងសង្គមជាតិ ដែលធ្វើឱ្យពួកគេមានឱកាសអាចទាញយកចំណាប់អារម្មណ៍របស់វិនិយោគិនដែលអាចអោយអ្នកវិនិយោគចាត់ទុកពួកគេជាអាជីវកម្មគោលដៅក្នុងការវិនិយោគ។ ការសិក្សាស្រាវជ្រាវនេះ បានដាក់គោលដៅដោយផ្តោតសំខាន់លើការសិក្សាទៅលើការយល់ឃើញរបស់សហគ្រិនស្ត្រី ដូច្នេះហើយ ការសិក្សាស្រាវជ្រាវនាពេលអនាគតគួរផ្តោតលើគោលគំនិត និងក្របខ័ណ្ឌរួមបញ្ចូលសមភាពយេនឌ័ររបស់ស្ថាប័នហិរញ្ញវត្ថុដែលលើកឡើងអំពីអន្តរប្រសព្វនៃបទពិសោធន៍របស់សហគ្រិនស្ត្រី។

# សេចក្ដីថ្លែងអំណរគុណ

តាំងនាមអោយអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា និង SHE គាំទ្រដោយ iDE យើងសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមចំណែកក្នុងគម្រោងស្រាវជ្រាវដ៏សំខាន់នេះ។

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រុមស្រាវជ្រាវរបស់យើង និងសហគ្រិនស្ត្រីដែលនៅក្នុងទីក្រុងភ្នំពេញ និងខេត្តបាត់ដំបងទាំង៦រូប ក្នុងការចូលរួមប្រមូលទិន្នន័យ និងផ្ដល់ជាចំណេះដឹងក្នុងការវិភាគលើការសិក្សាស្រាវជ្រាវនេះ តាំងពីដើមរហូតដល់ចប់ អរគុណសម្រាប់ពេលវេលាដ៏មានតម្លៃ ការចូលរួមដែលអស់ពីចិត្ត និងចូលរួមប្រកបដោយជំនាញដែលធ្វើអោយការសិក្សាស្រាវជ្រាវនេះមានអត្ថន័យ។

យើងមានអំណរគុណយ៉ាងក្រៃលែង ចំពោះការគាំទ្រដែលផ្ដល់ដោយគំនិតផ្ដួចផ្ដើមនៃការស្រាវជ្រាវ និងស្ដង់ដារវិនិយោគសម្រាប់សមធម៌យេនឌ័រ (ARISE) ដែលអនុវត្តដោយ ANDE, the Criterion Institute និង 2X Global តាមរយៈមូលនិធិដោយសប្បុរសពីរដ្ឋាភិបាលកាណាដា។

ជាចុងក្រោយ យើងសូមអរគុណអ្នកចូលរួមនៃការសិក្សានេះចំពោះការរួមចំណែកដែលមិនអាចកាត់ថ្លៃបានរបស់ពួកគេ។ សូមអរគុណចំពោះការគាំទ្រ ការរួមចំណែក ជំនួយ និងកិច្ចសហប្រតិបត្តិការ។

# I. សេចក្តីផ្តើម

អន្តរប្រសព្វនៃយេនឌ័រ ស្ថានភាពសេដ្ឋកិច្ច និងវិមាត្រសង្គមផ្សេងទៀតដើរតួនាទីយ៉ាងសំខាន់លើបទពិសោធន៍ធ្វើអាជីវកម្មរបស់សហគ្រិនស្ត្រី (WEs) ជាពិសេសអាជីវកម្មដែលចាត់ចូលជាសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម (MSMEs) រួមទាំងសមត្ថភាពរបស់ពួកគេក្នុងការសន្សំដើមទុនដែលត្រូវការក្នុងការពង្រីក និងធ្វើឱ្យអាជីវកម្មរបស់ពួកគេក្លាយជាអាជីវកម្មផ្លូវការ (ដែលដំណើរការអាជីវកម្មរបស់ពួកគេធ្វើតាមស្តង់ដានិងចុះបញ្ជីតាមផ្លូវច្បាប់ទៅតាមប្រភេទអាជីវកម្មរបស់ពួកគេ)។ ការសិក្សានេះពិនិត្យយ៉ាងយកចិត្តទុកដាក់លើបញ្ហាប្រឈមអន្តរប្រសព្វដែលសហគ្រាសធុនតូចបំផុត ខ្នាតតូច និងមធ្យមដែលដឹកនាំដោយសហគ្រិនស្ត្រីជួបប្រទះក្នុងការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ក៏ដូចជាផលប៉ះពាល់ជាបន្តបន្ទាប់លើឱកាសទទួលបានវិនិយោគរបស់ពួកគេ។

របាយការណ៍នេះរួមមានដូចជា៖ ទិដ្ឋភាពទូទៅនៃការរកឃើញការពិនិត្យឡើងវិញឯកសារសិក្សាស្រាវជ្រាវមុនៗ ការពន្យល់អំពីវិធីសាស្ត្រស្រាវជ្រាវ ការរកឃើញនៃការស្រាវជ្រាវ ការពិភាក្សាលើការរកឃើញទាំងនេះនិងចុងក្រោយការសន្និដ្ឋាន និងអនុសាសន៍។

## 1.1 ការសិក្សាស្រាវជ្រាវលើឯកសារផ្សេងៗ

បញ្ហាប្រឈមមួយក្នុងដំណើរការសិក្សាស្រាវជ្រាវអំពីឯកសារសិក្សាស្រាវជ្រាវមុនៗនៃសហគ្រាសធុនតូចបំផុត ធុនតូច និងមធ្យមនៅប្រទេសកម្ពុជា គឺមានគម្លាតព័ត៌មានជាច្រើន។ របាយការណ៍ពីកម្មវិធី Hidden in Plain Sight ពីកម្មវិធី Work and Opportunities for Women (WOW) រកឃើញថា ទោះបីជាមានការកើនឡើងនៃអាជីវកម្មដែលទទួលស្គាល់ពីសារៈសំខាន់នៃការប្រមូល និងវិភាគទិន្នន័យសមភាពយេនឌ័រក៏ដោយ ក៏នៅតែមានគម្លាតគួរឱ្យកត់សម្គាល់។ ក្រុមហ៊ុនពិបាកដឹងកន្លែងដែលត្រូវចាប់ផ្តើម ដើម្បីឆ្ពោះទៅរកការបង្រួមគម្លាតទិន្នន័យសមភាពយេនឌ័រទាំងនេះ ឬរបៀបវិភាគទិន្នន័យសមភាពយេនឌ័រដែលពួកគេមាន។ Support Her Enterprise Co., Ltd បានបោះពុម្ពផ្សាយសង្ខេបគោលនយោបាយផ្ទៃក្នុង (2023) ដែលបង្ហាញពីបញ្ហាប្រឈមសំខាន់ៗចំនួនបួន៖

1. ការទទួលបានព័ត៌មាន
2. ដំណើរការនៃការដាក់ពាក្យស្នើសុំប្រាក់កម្ចីស្មុគស្មាញ
3. តម្រូវការទ្រព្យបញ្ចាំសម្រាប់ការស្នើសុំប្រាក់កម្ចី និង
4. អត្រាការប្រាក់ខ្ពស់

ទោះបីជាមានការសិក្សា និងឯកសារដែលបានបង្កើតឡើងនិងចងក្រងទាក់ទងទៅនឹងភាពខុសគ្នានៃសមភាពយេនឌ័រនៅក្នុងបទពិសោធន៍ទទួលបានហិរញ្ញវត្ថុ ដោយសហគ្រិនស្ត្រីខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម (MSMEs) នៅប្រទេសកម្ពុជាក៏ដោយ ក៏នៅមានចំនុចចន្លោះប្រហោង ដែលមិនបានធ្វើការពិចារណាគ្រប់គ្រាន់លើភាពអន្តរប្រសព្វ និងផលប៉ះពាល់ដល់ឱកាសទទួលបានវិនិយោគរបស់សហគ្រិនស្ត្រី។

យោងតាមសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC, 2019) សហគ្រិនស្ត្រីជាម្ចាស់អាជីវកម្ម 61% នៃអាជីវកម្មទាំងអស់ - ខ្នាតតូចបំផុត តូច មធ្យម និងធំ - នៅក្នុងប្រទេសកម្ពុជា ដែលជាតួលេខដែលខ្ពស់ជាងប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍។ ប៉ុន្តែស្ត្រីភាគច្រើន (62%) គឺមានសហគ្រាសខ្នាតតូច។ អាជីវកម្មរបស់សហគ្រិនស្ត្រីជាធម្មតាមានទំហំតូចជាងបុរស ហើយភាគច្រើនស្ថិតក្នុងវិស័យចំនួន 4 ដែលមានចំនួន 97% នៃអាជីវកម្មដែលគ្រប់គ្រងដោយស្ត្រីទាំងអស់៖

- លក់ដុំ និងរាយ និងសេវាកម្ម (66%)
- កន្លែងស្នាក់នៅ និងអាហារ (17%)
- ការផលិតឬសិប្បកម្ម (10%)
- សេវាកម្មផ្សេងទៀត (7%)

យោងតាមការស្រាវជ្រាវរបស់ Swisscontact ស្តីពីការតភ្ជាប់ប្រព័ន្ធអេកូឡូស៊ីសហគ្រិននៅក្នុងរាជធានីភ្នំពេញ (2019) លទ្ធភាពក្នុងការទទួលបានជំនួយហិរញ្ញវត្ថុនៅតែមានឧបសគ្គគួរអោយកត់សំគាល់សំរាប់សហគ្រិនស្ត្រីមួយភាគធំនៅក្នុងប្រទេសកម្ពុជា ដូចដែលបានបង្ហាញនៅក្នុងការរកឃើញនៃការស្ទង់មតិ។ ការស្រាវជ្រាវរបស់ Swisscontact មានអ្នកចូលរួមចំនួន 398 នាក់ ដែលរួមមានសហគ្រិនចំនួន 312 នាក់ និងអង្គការគាំទ្រសហគ្រិន (ESOs) ចំនួន 86នាក់ ។ សហគ្រិនមកពី 18 វិស័យផ្សេងៗគ្នាត្រូវបានស្ទង់មតិ ដែល 50% នៃអ្នកឆ្លើយសំណួរតំណាងឱ្យ បី វិស័យគឺ វិស័យអាហារ និងភេសជ្ជៈ (23%) វិស័យសិប្បកម្ម និងសិល្បៈ (13%) និងវិស័យអប់រំ (10%) ។ មានតែមួយភាគបី នៃសហគ្រិនដែលបានស្ទង់មតិនៅក្នុងរបាយការណ៍ Swisscontact បានរាយការណ៍ថាបានទទួលមូលនិធិ។ ក្នុងចំណោមអ្នកដែលបានស្ទង់មតិនេះ 50% ទទួលបានប្រាក់កម្ចីស្តង់ដារពីស្ថាប័នហិរញ្ញវត្ថុ 24% ទទួលបានជំនួយ 15% ទទួលបានដើមទុនពីប្រភពផ្សេងទៀតដូចជាភាគហ៊ុន ហើយមាន 3% ទទួលបានប្រាក់កម្ចីសម្បទាន។

ទោះបីជារបាយការណ៍នេះ ផ្តល់នូវទិដ្ឋភាពទូទៅដ៏សម្បូរបែបនៃប្រព័ន្ធអេកូឡូស៊ីសហគ្រិនក៏ដោយ យ៉ាងណាម៉េញការសិក្សាស្រាវជ្រាវ ត្រូវបានផ្តោតសំខាន់លើអាជីវកម្មខ្នាតតូចនិងមធ្យម ដែលមានទីតាំងនៅរាជធានីនៃរាជធានីភ្នំពេញ មិនរួមបញ្ចូលអាជីវកម្មខ្នាតតូចបំផុតទេ។ សេដ្ឋកិច្ចប្រទេសកម្ពុជាជាសេដ្ឋកិច្ចដែលអាស្រ័យលើវិស័យធនាគារដែលក្នុងនោះធនាគារពាណិជ្ជជាអ្នកផ្តល់ផលិតផលឬសេវាកម្មហិរញ្ញវត្ថុចំបងនៅក្នុងផ្ទៃប្រទេស ជាមូលហេតុនាំអោយទិដ្ឋភាពនៃការវិនិយោគមានលក្ខណៈបែបអភិរក្ស ដែលអំនោយផលដល់អាជីវកម្មដែលកំពុងដំណើរការ ដោយឡែកមានការស្ទាក់ស្ទើរក្នុងការវិនិយោគលើអាជីវកម្មដែលមិនមានសម្ពាង ឬអាជីវកម្មស្ថិតក្នុងដំណាក់កាលត្រូវការការបណ្តាក់ទុនដោយសារតែមានហានិភ័យខ្ពស់។

### 1.1.1 តួនាទីរបស់ស្ថាប័នហិរញ្ញវត្ថុ

ស្ថាប័នហិរញ្ញវត្ថុ (FIs) រួមមានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFIs) ដើរតួនាទីក្នុងការបើកឱកាស (ឬបិទឱកាស) អោយសហគ្រាសធុនតូច និងមធ្យមដែលគ្រប់គ្រងដោយស្ត្រី មានការរីកចម្រើន ធ្វើអោយអាជីវកម្មមានស្តង់ដា

ឬប្រព្រឹត្តទៅតាមផ្លូវការរបស់ច្បាប់ និងធ្វើការពង្រីកអាជីវកម្មអោយរីកចម្រើន។ ការធ្វើអោយសហគ្រិនស្ត្រីមានលទ្ធភាពទទួលបានផលិតផលឬសេវាកម្មហិរញ្ញវត្ថុពីស្ថានប័នហិរញ្ញវត្ថុបានកាន់តែច្រើនគឺជាកូនសោរអាទិភាពជាសកលដែលនឹងអាចសម្រេចបាននូវការអភិវឌ្ឍមួយជារួមដោយបានបញ្ចូលសមភាពយេនឌ័រ។ ជារឿយៗស្ត្រីទំនងជាមានគណនីធនាគារតិចជាងបុរស ដែលកាត់បន្ថយសមត្ថភាពរបស់ពួកគេក្នុងការសន្សំ ខ្ចី និងគ្រប់គ្រងហានិភ័យដែលទាក់ទងនឹងគ្រួសារ និង/ឬអាជីវកម្ម (ធនាគារពិភពលោក, ២០១៤)។ យោងតាមរបាយការណ៍វិនិយោគ ទិដ្ឋភាពវិនិយោគតាមរយៈយេនឌ័រ (Gender Lens Investing Landscape) របស់មូលនិធិស្វីសខនធៈ (Swisscontact) និង មូលនិធិសន្តិភាពសាសាកាវ៉ា (Sasakawa Peace Foundation) ពីឆ្នាំ ២០២៤ មានស្ថាប័នហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលដូចជា ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME Bank) និងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) ដែលបង្កើតផលិតផលហិរញ្ញវត្ថុជាពិសេសតម្រូវសម្រាប់សហគ្រិនស្ត្រី (Swisscontact and Sasakawa Peace Foundation, 2024)។ របាយការណ៍ទាំងនោះលើកឡើងជាពិសេសពីធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ធនាគារស្ថាបនា និងធនាគារវីង ជាស្ថាប័នសំខាន់ៗដែលកំពុងធ្វើការជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកែលម្អលទ្ធផលសមភាពយេនឌ័រ តាមរយៈផលិតផល និងសេវាកម្មហិរញ្ញវត្ថុរបស់ពួកគេ។ ការសិក្សាស្រាវជ្រាវនោះ មានការចូលរួមពីសហគ្រិនចំនួន 200នាក់នៅរាជធានីភ្នំពេញ បាត់ដំបង និងសៀមរាប ដែលក្នុងនោះ 48% បានទទួលប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ (Fis) ក្នុងរយៈពេល 2 ឆ្នាំចុងក្រោយនេះគោលបំណងកម្ចីគឺយកដើមទុនដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ។ អ្វីដែលសំខាន់គឺ របាយការណ៍ស្រាវជ្រាវនោះបានរកឃើញថាសហគ្រាសដែលគ្រប់គ្រងដោយបុរស (50% នៃអ្នកចូលរួម) ទទួលបានប្រាក់កម្ចី និងទំហំនៃកម្ចីខ្ពស់ជាង (ជាមធ្យម 284,000 ដុល្លារ) បើប្រៀបធៀបទៅនឹងសហគ្រាសដែលគ្រប់គ្រងដោយស្ត្រី (46% នៃអ្នកឆ្លើយតប និងទំហំប្រាក់កម្ចីជាមធ្យម 240,000 ដុល្លារ) ។ ទោះជាយ៉ាងណាក៏ដោយ ភាគរយនៃអាជីវកម្មដែលបានទទួលការវិនិយោគក្នុងអំឡុងពេលនោះមានត្រឹមតែ 4% ប៉ុណ្ណោះ។

មីក្រូហិរញ្ញវត្ថុបានក្លាយជាចំណែកមួយដ៏សំខាន់ក្នុងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅអាស៊ី និងអាស៊ីអាគ្នេយ៍ដែលជាកន្លែងដែលវិសមភាពយេនឌ័រ និងភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចកើតមានឡើងក្នុងទម្រង់ជាប្រព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធភាពទទួលបានផលិតផល និងសេវាពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅតែជាបញ្ហាប្រឈមដែលគួរអោយកត់សម្គាល់។ តួនាទីយេនឌ័រជាលក្ខណៈប្រពៃណី រួមជាមួយនឹងអក្ខរកម្មផ្នែកហិរញ្ញវត្ថុដែលនៅមានកម្រិត បានរារាំងស្ត្រីក្នុងការទទួលបានប្រាក់កម្ចី និងចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូល (Mayoux, 1999; Rashid & Elder, 2009)។ របាយការណ៍សិក្សាស្រាវជ្រាវ បានគូសបញ្ជាក់ពីសារៈសំខាន់នៃការដោះស្រាយបញ្ហាទាំងនេះ ដើម្បីធានាបាននូវលទ្ធភាពនៃការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុរបស់មីក្រូហិរញ្ញវត្ថុដោយមានលក្ខណៈរួមបញ្ចូល និងសមធម៌។ លើសពីនេះ បញ្ហាប្រឈមប្រសព្វដែលប៉ះពាល់ដល់សមត្ថភាពរបស់ស្ត្រីក្នុងការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុមានច្រើនគួរអោយកត់សម្គាល់។ ការស្រាវជ្រាវ (Coleman, 2007; Banerjee et al., 2015) គូស

បញ្ជាក់ថា កត្តាដូចជា ពូជសាសន៍ ជាតិសាសន៍ និងសាវតាសេដ្ឋកិច្ចសង្គម ប្រសព្វគ្នាជាមួយសមភាពយេនឌ័រ ដែលបណ្តាលឱ្យលទ្ធភាពទទួលបានប្រាក់កម្ចី ខ្សែឥណទាន និងកម្មវិធីអប់រំហិរញ្ញវត្ថុមានលក្ខណៈខុសគ្នាៗ។

បញ្ហានេះកាន់តែធ្ងន់ធ្ងរទៅៗដោយសារកង្វះធនធាន។ របាយការណ៍របស់អង្គការសហប្រជាជាតិ (ឆ្នាំ ២០២១) បង្ហាញថា ប្រទេសកម្ពុជាមានប្រជាជនជិត ១៧ លាននាក់ ក្នុងនោះ ១២ លាននាក់រស់នៅជនបទ ដោយបែងចែកជាស្ត្រី ៥១ ភាគរយ និងបុរស ៤៩ ភាគរយ។ 49% នៃស្ត្រីនៅតំបន់ជនបទគឺមិនចេះអក្សរ ហើយ 35% បានបញ្ចប់ការសិក្សានៅសាលាបឋមសិក្សាតែប៉ុណ្ណោះ។ កម្រិតចំណេះដឹងដែលពួកគេមានទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ បរិយាកាសបទប្បញ្ញត្តិក្នុងប្រទេសកម្ពុជា និងកម្រិតនៃការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្លូវចិត្ត ដែលស្ត្រីទទួលបានពីមិត្តភក្តិ និងក្រុមគ្រួសាររបស់ពួកគេ មានឥទ្ធិពលលើទំនុកចិត្តដែលស្ត្រីមាន ទាក់ទងនឹងសមត្ថភាពរបស់ពួកគេក្នុងការចាប់ផ្តើមនិងដំណើរការអាជីវកម្ម។

ការសិក្សាអំពីផលប៉ះពាល់នៃមីក្រូហិរញ្ញវត្ថុលើការកាត់បន្ថយភាពក្រីក្រក្នុងចំណោមស្ត្រីនៅអាស៊ី និងអាស៊ីអាគ្នេយ៍បានបង្ហាញរូបភាពចម្រុះ។ ខណៈពេលដែលការស្រាវជ្រាវមួយចំនួន បង្ហាញពីលទ្ធផលវិជ្ជមាន រួមទាំងការបង្កើនប្រាក់ចំណូល និងបង្កើនសុខុមាលភាព (Duflo, 2012; Pitt & Khandker, 1998) ការសិក្សាផ្សេងៗទៀត បានបង្ហាញពីដែនកំណត់ដូចជាតម្រូវការក្នុងការធ្វើអន្តរាគមន៍ក្នុងសង្គមបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហាវិសមភាពជាលក្ខណៈប្រព័ន្ធ (សមធម៌កម្ពុជា & លីកាដូ, 2023; Hulme & Mosley, 1996; Montgomery et al., 1996)។ យោងតាមធនាគារជាតិនៃប្រទេសកម្ពុជា (NBC) មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសកម្មចំនួន 87 នៅចុងឆ្នាំ 2022 (NBC, 2022)។ បំណុលមីក្រូហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជា គឺជាបំណុលមួយក្នុងចំណោមបំណុលខ្ពស់បំផុតនៅលើពិភពលោក ដែលជាមធ្យម 4,000 ដុល្លារក្នុងមនុស្សម្នាក់នៅចុងឆ្នាំ 2021 ។ កម្ចីខ្នាតតូចសរុបនៅក្នុងប្រទេសកម្ពុជាមានចំនួន 16 ពាន់លានដុល្លារ និងបានកើនឡើងទ្វេដងចាប់តាំងពីឆ្នាំ 2019 (Licado & Equitable Cambodia, 2023)។ យោងតាមធនាគារជាតិនៃប្រទេសកម្ពុជា (NBC) គិតត្រឹមឆ្នាំ 2020 មានស្ត្រីចំនួន 2.27 លាននាក់ បានខ្ចីប្រាក់កម្ចីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលក្នុងនោះ 49% បានយកកម្ចីនោះមក ដើម្បីគាំទ្រដល់សកម្មភាពអាជីវកម្មរបស់ពួកគេ។

ការរៀបចំចងក្រងកម្មវិធីរបស់មីក្រូហិរញ្ញវត្ថុ តម្រូវទៅនឹងតម្រូវការរបស់ស្ត្រីនៅអាស៊ី និងអាស៊ីអាគ្នេយ៍ គឺជាកត្តាចាំបាច់សម្រាប់ភាពជោគជ័យជាប្រព័ន្ធ។ ការស្រាវជ្រាវ គូសបញ្ជាក់អំពីសារៈសំខាន់នៃកាលវិភាគសងត្រឡប់ដែលអាចបត់បែនបាន ផលិតផលហិរញ្ញវត្ថុដែលបានគិតគូរដល់វប្បធម៌ និងកម្មវិធីបណ្តុះបណ្តាលដែលធ្វើចំគោលដៅ (Mayoux, 2002; Armendariz & Morduch, 2010)។ គម្រោងដែលបានផ្តួចផ្តើមរៀបចំឡើងប្រកបដោយប្រសិទ្ធភាព អាចលើកកំពស់សេដ្ឋកិច្ចឬជីវភាពរបស់ស្ត្រី និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិអោយកាន់តែរីកចម្រើន។ បញ្ហាប្រឈមអន្តរប្រសព្វដែលជួបប្រទះដោយសហគ្រិនស្ត្រី MSMEs មានផលប៉ះពាល់ផ្ទាល់ចំពោះឱកាសទទួលបានការវិនិយោគរបស់ពួកគេ។ ការស្រាវជ្រាវមួយ បានណែនាំថា លទ្ធភាពទទួលបានដើមទុននិងធនធានមានកម្រិត អាចរារាំងដល់ការរីកចម្រើននៃអាជីវកម្មនិងការច្នៃប្រឌិត ដោយកំពុងបន្តបង្កើតជាប្រព័ន្ធដែលជះឥទ្ធពលអវិជ្ជមានដល់សហគ្រិនស្ត្រីដែលមានអត្តសញ្ញាណអន្តរប្រសព្វ (Sarasvathy, 2001; Marlow & McAdam, 2013)។

### 1.1.2 បទដ្ឋានសង្គម-វប្បធម៌ និងសិទ្ធិសេដ្ឋកិច្ចសង្គម

ប្រទេសកម្ពុជានៅតែត្រូវបានចាត់ទុកថាជាប្រទេស ដែលប្រកាន់យកនូវទស្សនៈប្រពៃណីលើតួនាទីយេនឌ័រ ហើយនៅតែប្រកាន់ខ្ជាប់នូវឋានានុក្រមសង្គម។ ទស្សនៈប្រកាន់ខ្ជាប់នេះ គឺអាចកត់សម្គាល់បានតាមរយៈការរំពឹងទុករបស់សង្គមលើឥរិយាបថ អាកប្បកិរិយា និងភាពជាស្ត្រី របស់ស្ត្រី។ ការរំពឹងទុកទាំងនេះ គឺពាក់ព័ន្ធទៅនឹងតួនាទីក្នុងគ្រួសារ ភាពជាម្តាយ និងការរ៉ាប់រងការងារក្នុងផ្ទះ (ឧ. ការចម្អិនអាហារ ការសម្អាត និងមើលថែទាំកុមារ) (UN Women Cambodia, n.d.) (Besheer, ២០២១)។ ទាំងនេះវាក៏ស្ថិតនៅក្នុងវប្បធម៌ខ្មែរផងដែរ ដែលច្បាប់ស្រីត្រូវបង្រៀនទៅក្មេងស្រី វាត្រូវបានគេមើលឃើញថាជាសំណុំនៃ "ច្បាប់" អំពីរបៀបក្លាយជា "ស្ត្រីប្រពៃ" (Ellen, 2013) ។ ស្ត្រីនៅកម្ពុជាមិនមានសេរីភាព ឬសិទ្ធិដូចបុរសទេ ដែលត្រូវបានកំណត់ដោយវប្បធម៌ខ្មែរ ហើយស្ត្រីនៅក្នុងប្រទេសកម្ពុជាត្រូវបានរឹតត្បិតលើផ្នែកជាច្រើន ដោយសារជំនឿថាបុរសមានឋានៈខ្ពស់ជាងស្ត្រី។ ជំនឿទាំងនេះដែលបណ្តាលអោយឈានដល់ការកំណត់ពីរបៀបដែលស្ត្រីគួរស្លៀកពាក់ ឥរិយាបថ និងអាកប្បកិរិយាដែលពួកគួរប្រតិបត្តិជារួម។ បុរសមិនត្រូវបានរងនូវសម្ពាធតាមស្តង់ដារដូចគ្នានឹងស្ត្រីទេ ពោលគឺពួកគេមិនប្រឈមមុខនឹងបទដ្ឋានវប្បធម៌ដែលកំណត់អាកប្បកិរិយា ហើយជាទូទៅពួកគេមិនប្រឈមមុខនឹងផលវិបាកផ្សេងៗដូចគ្នានឹងស្ត្រីទេ នៅពេលដែលពួកគេមានអាកប្បកិរិយាឃ្លាតពីបទដ្ឋានវប្បធម៌ (Higgs, 2022)។

ការសិក្សាសង្កត់ធ្ងន់លើផលប៉ះពាល់នៃបទដ្ឋានអយ្យកោ ដែលកំណត់កម្រិតការចល័តរបស់ស្ត្រី អំណាចនៃការសម្រេចចិត្ត និងសមត្ថភាពក្នុងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច (Goetz & Sen Gupta, 1996; Kabeer, 2005)។ ឧបសគ្គវប្បធម៌ជារឿយៗ មានចំណែកជាបញ្ហាប្រឈមសម្រាប់ស្ត្រីក្នុងការចូលរួមនៅក្នុងកម្មវិធីមីក្រូហិរញ្ញវត្ថុ។ យោងតាមវេទិកាសេដ្ឋកិច្ចពិភពលោក (ឆ្នាំ 2023) "របាយការណ៍គម្លាតយេនឌ័រសកល" របស់ពួកគេបង្ហាញថា អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក គឺជាតំបន់តែមួយគត់ដែលភាពអត់ការងារធ្វើសម្រាប់កម្មករស្ត្រីទាបជាងបុរស (ទាបជាង 1.0) ។ លើសពីនេះនៅក្នុងរបាយការណ៍របស់ធនាគារពិភពលោក (2022) ស្តីពី 'ការរួមចំណែកនៃកម្លាំងពលកម្មស្ត្រីនៅអាស៊ីខាងត្បូង' មជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង ពោលគឺមានតែមួយភាគបួនឬតិចជាងនេះប៉ុណ្ណោះ ដែលចូលរួមក្នុងទីផ្សារការងារ ដែលផ្ទុយពីការសិក្សាស្រាវជ្រាវប្រាំផ្សេងទៀតដែលស្ត្រីមានច្រើនជាងពាក់កណ្តាល (អាយុ 15-64) ចូលរួមក្នុងទីផ្សារការងារ។ នៅក្នុងប្រទេសកម្ពុជា ការចូលរួមនៃកម្លាំងពលកម្មស្ត្រីមានចំនួន 69.46% ក្នុងឆ្នាំ 2023 ដែលជាតួលេខខ្ពស់បំផុតក្នុងចំណោមប្រទេសអាស៊ីអាគ្នេយ៍។ អត្រារួមចំណែកនៃកម្លាំងពលកម្មស្ត្រីក្នុងឆ្នាំ 2023 នៅក្នុងតំបន់ទាំងមូលមានត្រឹមតែ 54.22% ប៉ុណ្ណោះ (The Global Economy, 2023)។

បទដ្ឋានវប្បធម៌ និងការរំពឹងទុករបស់សង្គមធ្វើឱ្យស្មុគស្មាញដល់ទិដ្ឋភាពហិរញ្ញវត្ថុរបស់សហគ្រិនស្ត្រី MSMEs ។ បញ្ហាប្រឈមមួយនៅក្នុងប្រទេសកម្ពុជា គឺកង្វះការយល់ដឹងអំពីទិដ្ឋភាពនៃការវិនិយោគលើសមភាពយេនឌ័រ (GLI) ដែលបណ្តាលអោយមានបញ្ហាប្រឈមទាក់ទងនឹងសមភាពយេនឌ័រ និងបទដ្ឋានសង្គម ពោលគឺប៉ះពាល់ដល់សមភាព

ផ្នែកហិរញ្ញវត្ថុ ដូចជាទ្រព្យបញ្ចាំ ភាពស្មុគស្មាញនៃការចុះបញ្ជី និងប្រាក់ចំណេញថយចុះដែលមានឥទ្ធិពលដោយផ្ទាល់លើសហគ្រាសខ្នាតតូចបំផុតរបស់សហគ្រិនស្ត្រី (Swisscontact និង Sasakawa Peace Foundation, 2024)។ ការវិភាគតាមបែបអន្តរប្រសព្វបង្ហាញថា ភាពលំអៀងខាងវប្បធម៌អាចប៉ះពាល់ដល់ការវាយតម្លៃលើលទ្ធភាពទទួលបានឥណទានរបស់ស្ត្រី និងកំណត់ពីឱកាសនៃការបង្កើតបណ្តាញរបស់ពួកគេ (Brush, 1992; Orser et al., 2011) ជាពិសេសនៅពេលដែលស្ត្រីជាអាណាព្យាបាលតែម្នាក់ឯង ឬជាស្ត្រីមេម៉ាយ។ លើសពីនេះ វិសមភាពយេនឌ័រប៉ះពាល់ដល់សិទ្ធិទទួលបានដីធ្លី ជាមួយនឹងកម្រិតកាន់តែខ្ពស់នៃអំពើហិង្សាក្នុងគ្រួសារ និងការបែកបាក់គ្រួសារនៅក្នុងប្រទេសកម្ពុជា (មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ដកស្រង់នៅក្នុង Klahaan 2020)។ ការយល់ដឹងអំពីសក្តានុពលទាំងនេះមានសារៈសំខាន់ណាស់សម្រាប់ធ្វើការអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុដែលមានភាពរួមបញ្ចូល។ បទដ្ឋានសង្គមកម្ពុជា (Anand, 2016) មានឥទ្ធិពលលើការថយចុះនៃកម្រិតការគោរពដែលស្ត្រីគួរទទួលបាន ហើយការខ្វះការគោរពនេះក៏មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ទំនុកចិត្តរបស់ស្ត្រីខ្លួនឯង និងភាពជោគជ័យ ឬបរាជ័យនៃអាជីវកម្មរបស់ពួកគេ។ ភ័ស្តុតាងបង្ហាញថាកង្វះទំនុកចិត្តនេះ ជះឥទ្ធិពលអវិជ្ជមានដល់កម្រិតនៃការព្យាយាមដើម្បីព័ត៌មានអំពីសេវាកម្មដែលត្រូវការដើម្បីជោគជ័យ (Naila Kabeer, 2002; Doneys, Doane, & Norm, 2020)។

### 1.1.3 ជាតិសាសន៍ និងពូជសាសន៍

បច្ចុប្បន្នមានការស្រាវជ្រាវលើកម្រិតផលប៉ះពាល់នៃការប្រកាន់ពូជសាសន៍ និងជាតិសាសន៍ដែលផ្តោតលើសហគ្រិនស្ត្រី។ អង្គការជនជាតិដើមភាគតិចនៃប្រទេសកម្ពុជា បញ្ជាក់ថា កម្ពុជាមានជនជាតិដើមភាគតិច ២២ ក្រុម ដែលមានប្រមាណ ២០% នៃប្រជាជន។ ភាគច្រើននៃពលរដ្ឋទាំងនេះរស់នៅភាគខាងជើង និងឦសាននៃប្រទេសកម្ពុជា ដូច្នេះហើយទំនងជាមិនមែនជាផ្នែកសំខាន់នៃអ្នកចូលរួមស្រាវជ្រាវគោលដៅរបស់យើងទេ។

នៅឆ្នាំ 2024 Impact Hub បានបង្កើតឧបករណ៍មួយសម្រាប់សហគ្រិនជនជាតិដើមភាគតិច ព្រោះពួកគេបានរកឃើញថាគំរូជំនួយអាជីវកម្មបច្ចុប្បន្នសម្រាប់សហគ្រិនជនជាតិដើមភាគតិចគឺ ពួកគាត់មិនមានអាចលទ្ធភាពប្រើប្រាស់ជំនួយនោះ និងមិនសាកសមជាមួយសហគ្រិនជនជាតិដើមភាគតិចទេ ដោយសារអ្នកផ្តល់ជំនួយផ្តោតលើប្រាក់ចំណេញជាជាងគោលដៅអភិវឌ្ឍន៍សហគមន៍។ ដើម្បីឱ្យមានការគាំទ្រប្រកបដោយប្រសិទ្ធភាពសម្រាប់សហគ្រិនជនជាតិដើមភាគតិច ចាំបាច់ត្រូវមានទំនាក់ទំនងយ៉ាងស៊ីជម្រៅជាមួយសហគមន៍ជនជាតិដើមភាគតិច និងការយល់ដឹងច្បាស់អំពីជំហរនិងគោលការណ៍នៃសហគ្រិនភាព។ លើសពីនេះ Impact Hub (2024) ណែនាំថា ការយល់ដឹងមានកម្រិតនៃប្រព័ន្ធសេដ្ឋកិច្ចទំនើប និងការលំបាកក្នុងការទទួលបានដើមទុនគឺជាឧបសគ្គដល់សហគ្រិនជនជាតិដើមភាគតិច។ ស្ថាប័នហិរញ្ញវត្ថុមានការស្ទាក់ស្ទើរក្នុងការទទួលយកទ្រព្យបញ្ចាំដែលជាទ្រព្យសម្បត្តិរួម ដែលបង្កើនបញ្ហាប្រឈមបន្ថែមទៀតចំពោះសហគ្រិនជនជាតិដើមភាគតិច ដោយសារមានការរើសអើងជាប្រព័ន្ធ និងឧបសគ្គផ្លូវច្បាប់ ដែលបានដាក់កម្រិតលើលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុកំរិតធម្មតា។ លើសពីនេះ ប្រព័ន្ធគាំទ្រការអភិវឌ្ឍន៍សំខាន់ៗ ទីផ្សារ និង

ឱកាសបង្កើតបណ្តាញមិនអាចធ្វើទៅបាន ដោយសារទីតាំងដាច់ស្រយាលនៃសហគមន៍ជនជាតិដើមភាគតិច ដែលធ្វើឲ្យពួកគេជួបការលំបាកក្នុងការធ្វើដំណើរ។

### 1.1.4 ស្ថានភាពសមត្ថភាព

មានការសិក្សាស្រាវជ្រាវជាច្រើនដែលបាន ដកស្រង់ចេញពីសៀវភៅណែនាំ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) សម្រាប់ជនពិការ រួមជាមួយ People in Need and Agile Development Group ដែលបោះពុម្ពក្នុងឆ្នាំ 2023។ ពួកគេបានចាត់ថ្នាក់ 'ឧបសគ្គពិការភាព' ជាច្រើនដែលប៉ះពាល់ដល់ការចូលរួមពេញលេញរបស់ ជនពិការ រួមទាំងអាកប្បកិរិយាសង្គម-វប្បធម៌ ដែលបណ្តាលអោយមានការរើសអើង និងការមិនរាប់បញ្ចូល ដោយផ្អែកលើការសន្មត់ថាជនពិការមិនអាចធ្វើការដោយឯករាជ្យ ឬបើកអាជីវកម្មបាន។ មានរបាំងឧបសគ្គជាធម្មជាតិ ជាច្រើនដែលប៉ះពាល់ដល់ការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធដោយសារកត្តារូបរាងកាយ។ ពួកគេសង្កត់ធ្ងន់លើសារៈសំខាន់នៃការបង្កើនការផ្តល់ព័ត៌មានក្នុងទម្រង់ផ្សេងៗគ្នាដោយប្រើពុម្ពអក្សរធំ និងក្រាហ្វិកសាមញ្ញ និងលើកទឹកចិត្តឱ្យមានច្បាប់ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការរបស់ជនពិការ។ មានឯកសារយោងពីផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៩-២០២៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ក្នុងការលើកកម្ពស់ការផ្តល់សិទ្ធិអំណាចតាមរយៈការគាំទ្រសម្រាប់ការអភិវឌ្ឍន៍អាជីវកម្មខ្នាតតូច ជាវិស័យអាទិភាពក្នុងការលើកកម្ពស់សុខុមាលភាព ដោយមើលឃើញពីអន្តរាគមន៍របស់ TVET និងការកែលម្អចំណេះដឹងផ្នែកគ្រប់គ្រងអាជីវកម្ម ជាវិធីសាស្ត្រដើម្បីសម្រេចបានការគាំទ្របន្ថែមទៀត។

Hanson (2020) បង្ហាញអំពីបញ្ហាប្រឈមដែលសហគ្រិនស្ត្រីដែលមានពិការភាព (WEDs) ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ (COVID-19)។ 100% នៃ សហគ្រិនស្ត្រីដែលមានពិការភាព(WEDs) ដែលត្រូវបានសម្ភាសមានការយល់ដឹងបានពេញលេញចំពោះកូវីដ-១៩ (COVID-19) មានដូចជារោគសញ្ញា របៀបនៃការឆ្លង និងវិធីសាស្ត្រកាត់បន្ថយអត្រាឆ្លងជំងឺនេះ។ ភាពតានតឹងចម្បង គឺមកពីការថយចុះនៃប្រាក់ចំណូល និងមានជំងឺរាតត្បាត។ 98% នៃអ្នកចូលរួមក្នុងការស្ទង់មតិមានអាជីវកម្មខ្នាតតូច ហើយ 93% នៃពួកគេបានជួបប្រទះការបាត់បង់ប្រាក់ចំណូលយ៉ាងគំហុក ចាប់តាំងពីការចាប់ផ្តើមនៃជំងឺរាតត្បាត (ខែមីនា 2020)។ អ្នកចូលរួមបានគិតថា ពួកគេគួរតែសម្របអាជីវកម្មរបស់ពួកគេ ដើម្បីទប់ទល់នឹងផលប៉ះពាល់នៃ COVID-19 នៅក្នុងខែមិថុនា។ នៅខែកញ្ញា 43% នៃអ្នកចូលរួមបានអនុវត្តវាយ៉ាងពេញលេញជាមួយនឹងអត្រាជោគជ័យ 23% ក្នុងចំណោមការសម្របសម្រួលទាំងអស់ដែលបានធ្វើ។ 43% នៃអ្នកឆ្លើយតបមានប្រាក់កម្ចីខ្នាតតូច ហើយ 46% នៃអ្នកទាំងនោះប្រឈមមុខការសងត្រលប់កម្ចី។ នៅពេលសួរថាតើពួកគេត្រូវការជំនួយអ្វីខ្លះដើម្បីគាំទ្រអាជីវកម្មរបស់ពួកគេ 50% បានឆ្លើយតបថាប្រាក់ និង 36% បានលើកឡើងពីតម្រូវការសម្រាប់ជំនាញគ្រប់គ្រងអាជីវកម្ម (Hanson 2020)។

ការស្រាវជ្រាវខ្នាតតូចនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សាធារណៈរដ្ឋឆេក (2023) ពិនិត្យលើការណែនាំអំពីការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងការបណ្តុះបណ្តាលសម្រាប់ជនពិការ។ ដូចមានចែងក្នុងរបាយការណ៍នេះ ជនពិការ ជាពិសេសជនក្រីក្រ ជួបប្រទះការរើសអើងក្នុងទម្រង់ និងផ្នែកផ្សេងៗក្នុងជីវិតរបស់ពួកគេ ទាំងក្នុងសង្គម និងលើរូបរាង

កាយ និងភាពមានកម្រិតក្នុងការទទួលបានសេវាថែទាំសុខភាព ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយសារបញ្ហាហិរញ្ញវត្ថុ។ កត្តាទាំងនោះហើយដែលបង្អាក់ពួកគេក្នុងការចូលរួមចំណែកក្នុងសកម្មភាពសេដ្ឋកិច្ចជាតិ ឬទទួលបានអត្ថប្រយោជន៍ពីសេដ្ឋកិច្ច (ដូចដែលបានលើកឡើងនៅក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សាធារណៈរដ្ឋឆេកឆ្នាំ 2023 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ 2018 ទំព័រ 09)។ របាយការណ៍នេះរួមបញ្ចូលទាំងឧបសគ្គធំៗដែលប៉ះពាល់ដល់ជនពិការ រួមមានអាកប្បកិរិយាដែលជនពិការមិនត្រូវបានរួមបញ្ចូលដោយសារតែកត្តាសង្គមនិងវប្បធម៌ដែលបានបង្កើតការសន្មត់លើជនពិការ។ ឧបសគ្គខាងបរិស្ថានឬរាងកាយ ទាក់ទងនឹងការចូលទៅកាន់កន្លែងណាមួយដែលមានឧបសគ្គ ធ្វើឱ្យពិបាកសម្រាប់អ្នកដែលមានពិការភាពលើរូបរាងកាយឬពិការភាពលើញ្ញាណណាមួយដែលធ្វើអោយពួកគាត់ពិបាកក្នុងការធ្វើដំណើរ ឬមិនអាចបែងចែកទិសឬទីតាំងបាន។ ព័ត៌មានឬទំនាក់ទំនង សំដៅលើកង្វះធនធានសម្រាប់ជនពិការដែលត្រូវការអ្នកបកប្រែ ឬដោយសារកត្តាភាពមានកម្រិតនៃចំនេះដឹងដែលធ្វើអោយពួកគេមិនអាចមានលទ្ធភាពទទួលបានព័ត៌មាន ឧបសគ្គស្ថាប័នសំដៅលើស្ថាប័នមួយចំនួនដែលបង្កឧបសគ្គដោយជំរុញឱ្យមានការរើសអើង និងគ្មានការគាំទ្រដល់ជនពិការ។

### 1.1.5 ការអប់រំ

ជាញឹកញាប់ស្ត្រីនៅមានកម្រិត ឬគ្មានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព និងការអភិវឌ្ឍន៍លើជំនាញ បើប្រៀបធៀបទៅនឹងបុរសជំនាន់របស់ពួកគេ។ ស្ត្រីនិងកុមារីតែងតែរងផលប៉ះពាល់អវិជ្ជមានដោយសារតែជំនឿវប្បធម៌។ របាយការណ៍របស់ Klahaan (2020) ចែងថា ជាទូទៅស្ត្រីនៅក្នុងប្រទេសកម្ពុជាត្រូវបានគេរំពឹងថានឹងបំពេញតួនាទីយេនឌ័រនិងគោរពប្រពៃណី។ នៅពេលដែលឪពុកម្តាយត្រូវបង្ខំចិត្តឱ្យយកកូនម្នាក់ ឬច្រើននាក់ឈប់រៀនដោយសារភាពក្រីក្រ កុមារទាំងនោះទំនងជាក្មេងស្រីជាជាងក្មេងប្រុស ដែលជាលទ្ធផលនៃភាពលំអៀងខាងវប្បធម៌ដែលផ្តល់តម្លៃខ្ពស់លើការអប់រំរបស់ក្មេងប្រុស។ Tuy (2019) បង្ហាញឱ្យឃើញថា មនុស្សជំនាន់មុននៅក្នុងសង្គមប្រទេសកម្ពុជា នៅតែប្រកាន់យកនូវមនោគមវិជ្ជាប្រពៃណី មានន័យថាសម្រាប់ស្ត្រីភាគច្រើន ពួកគេមិនអាច ឬគ្មានឱកាសបន្តការសិក្សាទាល់តែសោះ។ លទ្ធផលនេះមានន័យថាស្ត្រីនឹងពឹងផ្អែកលើបុរស ឬគ្រួសាររបស់ពួកគេសម្រាប់ជំនួយផ្នែកសេដ្ឋកិច្ច ព្រោះថាពួកគេនឹងត្រូវបានរារាំងក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ពួកគេ បង្កើនភាពអាស្រ័យលើ និងព្យាយាមសម្របតាមដល់ដៃគូបុរសរបស់ពួកគេ។ កង្វះការអប់រំនឹងធ្វើឱ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរទៅថ្ងៃអនាគត។ Kabeer (1999) អះអាងថា ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីត្រូវតែរួមបញ្ចូលសូចនាករផ្សេងៗគ្នា ដូចជាការចូលរួមក្នុងការសម្រេចចិត្ត សេរីភាពនៃការធ្វើដំណើរ និងឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីដែលបានទទួលការអប់រំ មានឱកាសប្រសើរជាងមុន និងមានឥទ្ធិពលវិជ្ជមានលើជីវិតរបស់ពួកគេនិងជីវិតរបស់កូនៗពួកគេផងដែរ (Obiagu, 2023)។ នេះបង្ហាញថា ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់គុណតម្លៃជីវិតស្ត្រីឱ្យកាន់តែប្រសើរឡើង ដោយផ្តល់ឱ្យពួកគេនូវឱកាសកាន់តែច្រើនក្នុងភាពឯករាជ្យ និងសេរីភាពជាងមុន ក្នុងនោះរួមមានសេរីភាព

សេដ្ឋកិច្ច ដែលអនុញ្ញាតឱ្យពួកគេទទួលបានអំណាចកាន់តែច្រើន ដោយសារសេរីភាពសេដ្ឋកិច្ចគឺជាមូលដ្ឋានគ្រឹះនៃការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ដែលអាចផ្តល់ឱកាសល្អៗសម្រាប់ពួកគេ (Kim, 2022)។

ហេង (២០២២) បញ្ជាក់ថា មានគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ហៅថា យុទ្ធសាស្ត្រនារីរតនៈ ដោយមានគោលដៅអភិវឌ្ឍ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី ក្នុងក្តីសង្ឃឹមក្នុងការសម្រេចបាននូវសមភាពយេនឌ័រ និងផ្តល់ឱកាសកាន់តែប្រសើរឡើងសម្រាប់ស្ត្រី។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងឆ្នាំចុងក្រោយនៃការអនុវត្តរបស់ខ្លួន (នារីរតនៈទី៤) ភាគរយនៃកុមារីដែលចុះឈ្មោះចូលរៀននៅបឋមសិក្សាបានធ្លាក់ចុះ ជាមួយនឹងអត្រាបោះបង់ការសិក្សានិងការបន្តថ្នាក់រៀន គឺជាបញ្ហាមួយទៀតជាមួយចំនួនសាលាអនុវិទ្យាល័យនៅមានកម្រិត។ ក្នុងចំណោមសិស្សដែលបានបញ្ចប់ថ្នាក់បឋមសិក្សា (87.4%) មានត្រឹមតែ 53.6% ប៉ុណ្ណោះដែលបានចុះឈ្មោះចូលរៀននៅមធ្យមសិក្សាទុតិយភូមិ ហើយបញ្ហានេះកាន់តែធំនៅតំបន់ជនបទនៃប្រទេសកម្ពុជា (ADB, 2014 យោងតាម Heng, 2022)។

### 1.1.6 ទំនោរផ្លូវភេទ និងការបង្ហាញអត្តសញ្ញាណយេនឌ័រចម្រុះ

Kong (2018) បញ្ជាក់ថា មានសកម្មភាព និងគម្រោងនានានៅក្នុងប្រទេសកម្ពុជា ដែលនិយាយអំពីសិទ្ធិ របស់ LGBTQIA+ ប៉ុន្តែហេតុផលសំខាន់សម្រាប់ការដកចេញគឺកង្វះការរួមបញ្ចូលផ្នែកហិរញ្ញវត្ថុ។ ពួកគេបញ្ជាក់បន្ថែមថា ដោយសារតែការរើសអើង ដែលក្រុម LGBTQIA+ ប្រឈមមុខ ធ្វើអោយភាពក្រីក្រក្នុងចំណោមសហគមន៍ LGBTQIA+ គឺជាបញ្ហាសំខាន់ក្នុងប្រទេសកម្ពុជា ដោយសារការអប់រំ និងការងារមិនត្រូវបានធានា ដែលបណ្តាលឱ្យមានបញ្ហាប្រឈមចំពោះការងារ ឬការរើសអើង និងការមិនរាប់បញ្ចូលនៅកន្លែងធ្វើការ។ អាស្រ័យហេតុនេះ ពួកគេច្រើនតែក្លាយជាអនាថា ឬងាកទៅធ្វើជាពេស្យាចារ។

Rocca (2018) ពន្យល់បន្ថែមអំពីបញ្ហាប្រឈមដែល LGBTQIA+ ជួបប្រទះក្នុងការព្យាយាមទទួលបានប្រាក់កម្ចី សាវតារបស់ពួកគេធ្វើឱ្យពួកគេពិបាក ខណៈដែលពួកគេជាច្រើនបានបោះបង់ការសិក្សា គ្រួសាររបស់ពួកគេបានបដិសេធពួកគេតាំងពីក្មេង ខ្ចីលុយពីអ្នកអោយកម្ចីក្រៅប្រព័ន្ធដើម្បីផ្គត់ផ្គង់ជីវភាព រស់នៅដោយចំណាយតិចជាងមួយដុល្លារក្នុងមួយថ្ងៃ។ ដើម្បីទទួលបានប្រាក់កម្ចីពួកត្រូវប្រឈមមុខជាមួយនឹងបញ្ហាបន្ថែមទៀតនៅពេលព្យាយាមបំពេញតាមតម្រូវការរបស់ស្ថាប័នដូចជា តម្រូវអោយមានអ្នកធានា - ជាធម្មតាសមាជិកគ្រួសារ ឬមិត្តភ័ក្តិ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេបានរស់នៅដាច់ដោយឡែក មានបំណុលច្រើនរួចទៅហើយ ហើយមិនមានអ្នកណាធានាពួកគេទេ។ ការចាកចេញពីផ្ទះតាំងតែពីក្មេងមានន័យថា ពួកគេក៏មិនមានឱកាសប្រមូលទ្រព្យសម្បត្តិដូចជាម៉ូតូ ឬអចលនទ្រព្យណាមួយបានឡើយ។

### 1.1.7 ការគាំទ្របទប្បញ្ញត្តិ

គោលនយោបាយរបស់រាជរដ្ឋាភិបាល និងក្របខ័ណ្ឌស្ថាប័នដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំបរិយាកាសសម្រាប់មីក្រូហិរញ្ញវត្ថុ និងការទាក់ទាញការវិនិយោគនៅក្នុងតំបន់អាស៊ី និងអាស៊ីអាគ្នេយ៍។ អ្នកស្រាវជ្រាវ (Hossain,

2010; Sriram, 2014) បានជជែកវែកញែកអំពីតម្រូវការក្នុងការបន្សុីគោលនយោបាយជាមួយនឹងយុទ្ធសាស្ត្រសមភាពយេនឌ័រ ដោយអាចធានាថា ក្របខ័ណ្ឌបទប្បញ្ញត្តិនានាគាំទ្រដល់ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យហិរញ្ញវត្ថុជាផ្លូវការ។ ការទទួលស្គាល់លើបញ្ហាអន្តរប្រសព្វ តម្រូវឱ្យមានវិធីសាស្ត្រច្បាស់លាស់ចំពោះការអន្តរាគមន៍លើគោលនយោបាយ និងការគាំទ្រពីស្ថាប័នដែលមានចន្លោះប្រហោង។ អ្នកស្រាវជ្រាវ (Morrison et al., 2011; Allen et al., 2019) អ្នកតស៊ូមតិសម្រាប់គោលនយោបាយឆ្លើយតបសមភាពយេនឌ័រ ដែលពិចារណាពីតម្រូវការលើក្នុងរូបភាពផ្សេងៗគ្នារបស់សហគ្រិនស្ត្រី ដោយដាក់គោលដៅបញ្ចូលកម្មវិធីការណែនាំក្នុងការធ្វើអាជីកម្ម និងឧបករណ៍ហិរញ្ញវត្ថុដែលបានធ្វើឡើងដើម្បីដោះស្រាយបញ្ហាអន្តរប្រសព្វ។

យុទ្ធសាស្ត្ររួមបញ្ចូលហិរញ្ញវត្ថុឆ្នាំ ២០១៩-២០២៥ របស់ប្រទេសកម្ពុជា ប្តេជ្ញាបង្កើនលទ្ធភាពទទួលសេវាហិរញ្ញវត្ថុដែលមានគុណភាពនិងផ្លូវការពី ៥៩% ទៅ ៧០% និងធានាថាភាគរយស្ត្រីដែលត្រូវបានមិនបូកបញ្ចូលពី ២៧% ទៅ ១៣% ក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥៖ សមភាពយេនឌ័រ ( NBC, 2019) ។ យុទ្ធស្រាស្តនេះត្រូវបានប្តេជ្ញាក្នុងបង្កើតផលិតផលហិរញ្ញវត្ថុជាពិសេសសម្រាប់ស្ត្រី ជាពិសេសផ្តោតលើផ្នែកដែលការបូកបញ្ចូលនៅមានកម្រិតទាប ដូចជាឥណទានសម្រាប់ស្ត្រីវ័យក្មេងនិងមានការងារធ្វើ ក៏ដូចជាការសន្សំសម្រាប់ស្ត្រីវ័យចំណាស់។ នេះរួមបញ្ចូលទាំងការសង្កត់ធ្ងន់កាន់តែខ្លាំងលើ "បទប្បញ្ញត្តិស្តីពីការការពារអ្នកប្រើប្រាស់ដោយគិតពីសមភាពយេនឌ័រ" ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីក៏ប្រឈមមុខនឹងបញ្ហាមួយចំនួនទៀតដូចជា ភាពមានកម្រិតលើលទ្ធភាពទទួលបានការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ឥណទានផ្លូវការ និងការបង្កើតបណ្តាញ ជម្រើសតិចជាងមុនសម្រាប់ការធ្វើដំណើរ និងលទ្ធភាពក្នុងការចូលរួមដោយផ្ទាល់ ចំណេះដឹងអាជីវកម្មមិនគ្រប់គ្រាន់ និងកម្រិតទំនុកចិត្តទាបនៅពេលប្រៀបធៀបជាមួយដៃគូជាបុរសរបស់ពួកគេ។ ស្ត្រីមានទំនោរមិនមានវត្ថុបញ្ចាំបែបប្រពៃណីដូចជា ដី ផ្ទះ សាច់ប្រាក់ និងទ្រព្យសម្បត្តិផ្សេងទៀត ដែលនាំឱ្យមានគុណវិបត្តិនៅពេលស្វែងរកប្រាក់កម្ចី ឬមិនមានលទ្ធភាពទទួលបានឥណទានផ្លូវការ ដោយហេតុនេះហើយដែលធ្វើអោយមានការរាំងស្ទះក្នុងការដាក់ទុនដែលអាចអោយពួកគេឈានដល់ កម្រិតសហគ្រិនភាព។

### 1.1.8 ឥទ្ធិពលលើការវិនិយោគជាបន្តបន្ទាប់

Swisscontact និង Sasakawa Peace Foundation (2024) បានរកឃើញថា សម្រាប់ការទទួលបានហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅប្រទេសកម្ពុជាគឺមានតម្រូវការយ៉ាងខ្លាំង។ ក្នុងចំណោមអ្នកចូលរួមការស្ទង់មតិរបស់ពួកគេ សហគ្រាសដែលគ្រប់គ្រងដោយស្ត្រីដែលមិនបានចុះបញ្ជី ត្រូវការដើមទុនខ្ពស់ជាង សហគ្រាសដែលគ្រប់គ្រងដោយបុរស។ ទោះបីជាជាក់ស្តែងសហគ្រាសដែលគ្រប់គ្រងដោយបុរសត្រូវការដើមទុនច្រើនជាងក៏ដោយ គម្លាតហិរញ្ញប្បទានដែលរំពឹងទុកសម្រាប់សហគ្រាសដែលគ្រប់គ្រងដោយស្ត្រីមានចំនួន 6.4 ពាន់លានដុល្លារ បើធៀបនឹង 4.1 ពាន់លានដុល្លារសម្រាប់សហគ្រាសដែលគ្រប់គ្រងដោយបុរស។ សហគ្រិនស្ត្រីក៏ស្នើសុំការគាំទ្របន្ថែមទៀតសម្រាប់

ការសម្របសម្រួលផ្នែកហិរញ្ញវត្ថុ ការផ្តល់ជំនាញ និងការទទួលបានស្ថេរភាពទីផ្សារដែលមិនផ្លាស់ប្តូរជាមួយនឹងទំហំអាជីវកម្មរបស់ពួកគេ។

មូលនិធិអភិវឌ្ឍន៍ និងសាធារណៈមួយចំនួនគាំទ្រគម្រោង ឬកម្មវិធីដែលមានពេលវេលាកំណត់ ដំណើរការជាកាតាលីករជាជាងការផ្តួចផ្តើមប្រកបដោយនិរន្តរភាព។ លើសពីនេះ មូលនិធិមួយចំនួនត្រូវបានកំណត់លក្ខណៈជាការផ្តត់ផ្គង់ជាជាងការតម្រង់ទិសអាជីវកម្មទាំងនោះ។ នេះមានន័យថាមូលនិធិតម្រូវលើអាទិភាពរបស់អ្នកផ្តល់ទុនជាជាងតម្រូវការរបស់ទីផ្សារអ្នកត្រូវការជំនួយ ក្នុងករណីនេះអ្នកត្រូវការជំនួយគឺសហគ្រិនស្ត្រី។ បញ្ហាទាំងនេះបញ្ជាក់ពីតម្រូវក្នុងការកែរតម្រូវលើប្រតិបត្តិការក្នុងការផ្តល់ជំនួយពីខាងក្រោមកលើសហគមន៍ដែលត្រូវការជំនួយ ដែលជាការធានាបាននូវនិរន្តរភាព និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងស្របតាមគោលដៅរយៈពេលវែងរបស់សហគមន៍។ ជាក់ស្តែង កង្វះលទ្ធភាពទទួលបានហិរញ្ញប្បទាននៅដំណាក់កាលដំបូង ពីប្រភពកម្ចីដែលត្រូវបានចាត់ទុកថាអាចដាក់ពាក្យយកកម្ចីបានដូចជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើលទ្ធភាពទទួលបានការវិនិយោគជាបន្តបន្ទាប់។ ស្រដៀងគ្នាទៅនឹងបញ្ហាប្រឈមនានាដែលមានបទពិសោធន៍ក្នុងការទទួលបានហិរញ្ញវត្ថុ មានកត្តាជាច្រើនដែលប៉ះពាល់ដល់លទ្ធភាពទទួលបានការវិនិយោគរបស់សហគ្រិនស្ត្រី រួមទាំងកត្តាសមភាពយេនឌ័រដែលប៉ះពាល់ដល់ចំនួនផ្គូរផ្គងវិនិយោគដែលធ្វើឡើងដោយស្ត្រីធៀបនឹងបុរស និងវិសមភាពយេនឌ័រកើតឡើងដោយអចេតនា ពីអ្នកវិនិយោគក្នុងការជ្រើសរើសសហគ្រិន។ បញ្ហាប្រឈមទាំងនេះ ត្រូវបានកើតឡើងនៅក្នុងដំណាក់នៃការរីកចម្រើននៃអាជីវកម្មដែលបានលើកយកមកសិក្សាដោយបញ្ហាអន្តរប្រសព្វខាងលើ។

## 1.2 សេចក្តីសង្ខេបនៃការពិនិត្យឯកសារផ្សេងៗ

ការសិក្សាពិនិត្យលើឯកសារពាក់ព័ន្ធផ្សេងៗ គូសបញ្ជាក់ពីសារៈសំខាន់នៃការទទួលស្គាល់ និងដោះស្រាយបញ្ហាអន្តរប្រសព្វដែលសហគ្រិនស្ត្រី MSMEs ជួបប្រទះក្នុងដំណើរការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុ។ ស្ត្រី និងហិរញ្ញវត្ថុនៅអាស៊ី និងអាស៊ីអាគ្នេយ៍បង្ហាញពីអន្តរកម្មដ៏ស្មុគស្មាញនៃកត្តាវប្បធម៌ សេដ្ឋកិច្ច និងស្ថាប័នដែលមានឥទ្ធិពលលើបទពិសោធន៍របស់ស្ត្រីក្នុងការពង្រឹងអំណាចសេដ្ឋកិច្ចរបស់ពួកគេ។ ការយល់ដឹងដ៏ទូលំទូលាយអំពីអន្តរប្រសព្វរវាងសមភាពយេនឌ័រជាមួយ ជាតិសាសន៍ ពណ៌សម្បុរ និងស្ថានភាពសេដ្ឋកិច្ចសង្គម គឺមានសារៈសំខាន់សម្រាប់ការរៀបចំគោលនយោបាយ និងអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព។

ខណៈពេលដែលបញ្ហាប្រឈមនៅតែបន្តកើតមាន មានមតិមួយលើកឡើងថា ការអន្តរាគមន៍ចំគោលដៅដែលត្រូវបានធ្វើឡើងដោយការស្វែងយល់យ៉ាងស៊ីជម្រៅអំពីបរិបទក្នុងស្រុក អាចបង្កើនប្រសិទ្ធភាពនៃកម្មវិធីហិរញ្ញវត្ថុសម្រាប់ស្ត្រី។ នៅពេលដែលវិស័យនៃភាពជាសហគ្រិនមានការវិវឌ្ឍ ការស្រាវជ្រាវ និងការគំនិតផ្តួចផ្តើម ត្រូវតែប្រកាន់យកនូវទិដ្ឋភាពអន្តរប្រសព្វ ដើម្បីធានាបាននូវការរួមបញ្ចូល សមធម៌ និងការផ្តល់សិទ្ធិអំណាច ដល់ស្ត្រីនៅគ្រប់ជ្រុងនៃ ធុរកិច្ច

ចម្រុះ។ ការស្រាវជ្រាវ និងគំនិតផ្តួចផ្តើមគោលនយោបាយ គួរតែបន្តសង្កត់ធ្ងន់លើសក្តានុពលក្នុងតំបន់ ជំរុញជាប្រព័ន្ធក្នុងការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ចដល់ស្ត្រី និងរួមចំណែកដល់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ដូច្នេះ ការសិក្សានេះមានគោលបំណងស្វែងយល់ពីបញ្ហាប្រឈមអន្តរប្រសព្វ (ឧទាហរណ៍ អាយុ ស្ថានភាពសមត្ថភាព សាសនា សមាសភាពគ្រួសារ និង/ឬនិន្នាការផ្លូវភេទ) ដែលប៉ះពាល់ដល់ MSMEs សហគ្រិនស្ត្រីក្នុងការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុ និងការវិនិយោគជាបន្តបន្ទាប់។ ដូចនេះ ការសិក្សានេះនឹងឆ្លើយតបនឹងសំណួរស្រាវជ្រាវដូចខាងក្រោម៖

- តើអ្វីជាបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វដែលជះឥទ្ធិពលដល់សហគ្រិនស្រីខ្នាតតូច និងមធ្យម (WSMEs) ក្នុងការទទួលបានសេវារបស់ស្ថាប័នហិរញ្ញវត្ថុ (ផលិតផល សេវាកម្ម ការវិនិយោគ)?
- តើមានក្របខ័ណ្ឌយេនឌ័រអ្វីខ្លះដែលស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់ដើម្បីគាំទ្រដល់សហគ្រិនស្ត្រីខ្នាតតូច និងមធ្យម (WSMEs) ដើម្បីអភិវឌ្ឍ និងឆ្លើយតបទៅនឹងអាជីវកម្មរបស់ពួកគេ និងធ្វើឱ្យអាជីវកម្មរបស់ពួកគេប្រសើរឡើង?
- តើស្ថាប័នហិរញ្ញវត្ថុគួរធ្វើដូចម្តេចដើម្បីបញ្ឈប់នូវផលប៉ះពាល់នៃផ្នែកដែលជាបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វរបស់សហគ្រិនស្ត្រីខ្នាតតូច និងមធ្យម (WSMEs)?

## II. វិធីសាស្ត្រស្រាវជ្រាវ

វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ត្រូវបានប្រើដើម្បីប្រមូលទិន្នន័យ និងឆ្លើយសំណួរស្រាវជ្រាវដែលបានបង្ហាញខាងលើ។ ក្រុមស្រាវជ្រាវបានអនុវត្តវិធីសាស្ត្រសំខាន់ៗចំនួនបួនសម្រាប់ការសិក្សាស្រាវជ្រាវនេះ៖

1. ការប្រើប្រាស់វ៉ែនតាយេនឌ័រ (Genders Lens)៖ គិតគូរពីភាពខុសគ្នារវាងបុរស និងស្ត្រី នៅពេលវាយតម្លៃស្ថានភាព វិធីសាស្ត្រ ឬកម្មវិធី
2. វិធីសាស្ត្រស្រាវជ្រាវបែបហ្វេមមីនីស (Feminist Action Research)៖ ការស្រាវជ្រាវដែលអោយក្រុមគោលដៅចូលរួមយ៉ាងសកម្មក្នុងការប្រមូលទិន្នន័យ និងដំណើរការនៃការវាយតម្លៃ។
3. យេនឌ័រនៅកន្លែងការងារ (Gender at Work)៖ ក្របខណ្ឌវិភាគ ដែលបង្ហាញពី ទំនាក់ទំនងអន្តរកម្ម រវាងសមភាពយេនឌ័រ អំណាច និងស្ថាប័នពាក់ព័ន្ធ។
4. អន្តរប្រសព្វ (Intersectionality)៖ លក្ខណៈអន្តរទំនាក់ទំនងនៃធម្មជាតិនៃការបែងចែកសង្គម ដូចជាពូជសាសន៍ ឋានៈ និងយេនឌ័រ ដែលត្រួតលើគ្នាដើម្បីបង្កើតប្រព័ន្ធឯករាជ្យនៃការរើសអើង និង/ឬគុណវិបត្តិ។

វិធីសាស្ត្រជាច្រើន ត្រូវបានអនុវត្តដើម្បីគិតជានិច្ចលើជំហរផ្ទាល់ខ្លួនរបស់អ្នកស្រាវជ្រាវ រួមជាមួយនឹងការគោរពអ្នកចូលរួមស្រាវជ្រាវ ដោយយកចិត្តទុកដាក់គោរពស្វ័យភាព សុវត្ថិភាព និងឯកជនភាពរបស់ពួកគេ ក្នុងដំណើរការ

ស្រាវជ្រាវមួយនេះ និងស្វែងយល់អំពីទិន្នន័យដែលទទួលបាន និងបកស្រាយពីទិន្នន័យទាំងនោះដែលអាចជួយផ្តល់អំណាចដល់ក្រុមស្ត្រីចម្រុះដែលយើងបានធ្វើការស្ទង់មតិជាមួយ។ ខុសពីការស្រាវជ្រាវបែបប្រពៃណីដែលផ្តោតលើការប្រមូលផ្តុំទិន្នន័យ វិធីសាស្ត្ររបស់យើងបានផ្តល់អាទិភាពលើបទពិសោធន៍ និងទស្សនៈបុគ្គលដែលប្រមូលបានដោយប្រើវិធីសាស្ត្រ ពិភាក្សាក្រុម និងការសម្ភាសន៍ស៊ីជម្រៅអំពីអាជីវកម្មរបស់ពួកគេ បញ្ហាប្រឈមអន្តរប្រសព្វក្នុងការទទួលបានហិរញ្ញវត្ថុ និងការណែនាំសម្រាប់ស្ថាប័នហិរញ្ញវត្ថុ (FIs) ទាក់ទងនឹងផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលមានស្រាប់។

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបហ្វេមមីនីស (Feminist Action Research) មិនត្រឹមតែបង្កើនទំហំទិន្នន័យដែលប្រមូលបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយយើងឱ្យទទួលស្គាល់ និងចែករំលែកបទពិសោធន៍រវាងអ្នកចូលរួមផងដែរ។ ដោយធ្វើការជាមួយសហគ្រិនស្ត្រីចំនួន 6 នាក់ ដែលត្រូវបានបណ្តុះបណ្តាលជាអ្នកស្រាវជ្រាវ ហើយក្រុមស្រាវជ្រាវបានធានាថា ចំណេះដឹងអំពីហ្វេមមីនីស និងរបបអាណានិគមត្រូវបានប្រមូល និងវិភាគសម្រាប់គោលបំណងនៃការសិក្សានេះ។

## 2.1 ការប្រមូលទិន្នន័យ

**សិក្សាពីប្រភពឯកសាផ្សេងៗ ច្បាប់ និងឯកសារគោលនយោបាយដែលពាក់ព័ន្ធ៖** ការសិក្សាពីឯកសាផ្សេងៗបានប្រើជាចំណុចចាប់ផ្តើមនៃគោលនយោបាយសង្ខេបរបស់ HE's ស្តីពី 'បញ្ហាប្រឈមរបស់សហគ្រិនស្ត្រីក្នុងការទទួលបានហិរញ្ញវត្ថុ' ក្នុងឆ្នាំ 2022 ដែលបង្ហាញពីបញ្ហានៃការត្រៀមខ្លួនក្នុងការធ្វើអាជីវកម្ម តម្រូវការទ្រព្យបញ្ចាំ អត្រាការប្រាក់ខ្ពស់ និង ដំណើរការស្មុគស្មាញនៃការស្នើសុំកម្ចី។ ការសិក្សាដែលធ្វើឡើងដោយ GADC ស្តីពីការរំលោភសិទ្ធិដីធ្លីដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅប្រទេសកម្ពុជាក៏ត្រូវបានយកមកសិក្សាបន្ថែម។ ការស្រាវជ្រាវនេះមានអន្តរប្រសព្វជាមួយនឹងការសិក្សាពីទិដ្ឋភាព GLI ដែលធ្វើឡើងដោយ Swisscontact Cambodia និង Sasakawa Peace Foundation ចន្លោះខែសីហា ដល់ខែធ្នូ ឆ្នាំ 2023។ បន្ថែមពីលើប្រភពធនធានសំខាន់ៗទាំងបីនេះ ការសិក្សាស៊ីជម្រៅលើការស្រាវជ្រាវផ្សេងៗ និងការសិក្សាទៅលើការករណីសិក្សាផ្សេងៗត្រូវបានធ្វើឡើងយកមកសិក្សា។

**ការសម្ភាសន៍ស៊ីជម្រៅ (IDIs) ការពិភាក្សាជាក្រុមជាមួយក្រុមគោលដៅ (FGDs) និងការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ (KIIs)៖** ការសម្ភាសន៍ បានអនុញ្ញាតឲ្យអ្នកស្រាវជ្រាវក្នុងតំបន់ សួរសំណួរដែលស្មុគស្មាញ ស៊ីជម្រៅ និងសុំការបំភ្លឺពីអ្នកផ្តល់បទសម្ភាសន៍បាន។ អ្នកផ្តល់បទសម្ភាសន៍ បានប្រាប់រឿងរ៉ាវរបស់ពួកគេជាភាសានិយាយសាមញ្ញរបស់ពួកគេដែលបានអនុញ្ញាតិឱ្យអ្នកស្រាវជ្រាវក្នុងតំបន់ យល់កាន់តែស៊ីជម្រៅអំពីបញ្ហារបស់ពួកគេ។ ការសម្ភាសន៍ត្រូវបានធ្វើឡើងទម្រង់ពាក់កណ្តាល ប្រហែល 40-60 នាទីក្នុងមួយបទសម្ភាសន៍។ លទ្ធផលដែលបានមកពីការសម្ភាសន៍គឺអាចផ្ទៀងផ្ទាត់ និងបំពេញបន្ថែមអោយការសន្និដ្ឋាន។ ដោយសារទំហំគំរូដើមសម្រាប់ការ

សិក្សាបានកំនត់ចំនួនសហគ្រិនស្ត្រីចំនួន 100នាក់ ពួកយើងបានធ្វើការសម្ភាសន៍ស៊ីជម្រៅ(IDIs)ទៅកាន់ សហគ្រិនស្ត្រី ៥២នាក់ (២នាក់ជា LGBTQI+ ១នាក់ជាស្ត្រីដែលមានពិការភាព) និងធ្វើការសម្ភាសន៍ជាក្រុមជាមួយក្រុមគោលដៅ (FGDs) ជាមួយសហគ្រិនស្ត្រីចំនួន ៤៣នាក់ (៩នាក់ជាស្ត្រីដែលមានពិការភាព) ។ លើសពីនេះ យើងបាន សម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់(KIIs) ចំនួន 3 ជាមួយស្ថាប័នដែលផ្តោតលើស្ត្រី និងអន្តរប្រសព្វ និងលទ្ធភាពទទួល បានដើមទុន។

ការជ្រើសរើសអ្នកចូលរួមសម្ភាសន៍គឺផ្អែកលើគំរូបាល់ព្រិល (បច្ចេកទេសជ្រើសរើសអ្នកចូលរួមក្នុងការស្រាវជ្រាវ ត្រូវបានស្នើសុំឱ្យជួយអ្នកស្រាវជ្រាវក្នុងការកំណត់ប្រធានបទសក្តានុពលផ្សេងៗទៀត) ដោយអនុវត្តតាមលក្ខណៈវិនិច្ឆ័ យក្នុងការជ្រើសរើសដូចខាងក្រោម៖ (1) ម្ចាស់ MSME ត្រូវបានកំណត់អត្តសញ្ញាណជាស្ត្រី (2) អាជីវកម្មដែលដំណើរ ការនៅក្នុងរាជធានីភ្នំពេញ និង/ឬខេត្តបាត់ដំបង និង (3) ស្ត្រីដែលមានបទពិសោធន៍ចម្រុះ (ឧទាហរណ៍ អាយុ ស្ថានភាព សមត្ថភាព សាសនា សមាសភាពគ្រួសារ និង/ឬនិន្នាការផ្លូវភេទ)។ ដោយសារព្រំដែននៃការសិក្សានេះមានកម្រិត ការ ពិចារណាជាក់ស្តែងត្រូវបានធ្វើឡើងដើម្បីកំណត់គោលដៅទៅលើភូមិសាស្ត្រនៅខេត្តបាត់ដំបង និងរាជធានីភ្នំពេញ។ ទី តាំងទាំងនេះត្រូវបានជ្រើសរើសដោយសារតែអង្គការទាំងពីរមានបទពិសោធន៍ធ្វើការយ៉ាងជិតស្និតជាមួយអ្នកនៅក្នុង តំបន់ទាំងនេះ ដែលអនុញ្ញាតឱ្យយើងប្រៀបធៀបភាពខុសគ្នានៃប្រភេទអាជីវកម្ម (ទំហំ និងវិស័យ) សេវាហិរញ្ញវត្ថុដែល មានស្រាប់ និងរវាងប្រជាសាស្ត្រទីក្រុង និងជនបទ។

**ការគិតគូរទៅលើក្រមសីលធម៌ និងសុវត្ថិភាព៖** ក្រុមស្រាវជ្រាវបានអនុវត្តយ៉ាងតឹងរ៉ឹងតាមស្តង់ដារក្រមសីលធម៌ ដូចជាគោលការណ៍មិនបង្កគ្រោះថ្នាក់ ការការពារភាពអនាមិក និងការសម្ងាត់របស់អ្នកចូលរួមស្រាវជ្រាវ ធានាបាននូវការ យល់ព្រមជាលាយលក្ខណ៍អក្សរ (រួមទាំងរូបភាពដែលថតបានក្នុងករណីសមស្រប និងដោយមានការយល់ព្រមជា លាយលក្ខណ៍អក្សរ) ភាពយកចិត្តទុកដាក់ចំពោះបរិបទសង្គម និងវប្បធម៌ និងអនុវត្តបាននូវសុចរិតភាព និងភាពស្មោះ ត្រង់ នៅពេលប្រស្រ័យទាក់ទងជាមួយភាគីពាក់ព័ន្ធទាំងអស់។ លើសពីនេះ ក្រុមការងារប្រមូលទិន្នន័យបានប្រកាន់ខ្ជាប់ នូវគោលការណ៍ដូចខាងក្រោម៖

- ព័ត៌មានពេញលេញ និងច្បាស់លាស់អំពីការងារការស្រាវជ្រាវត្រូវបានផ្តល់ជូនអ្នកចូលរួមក្នុងការស្រាវជ្រាវ មុន ពេលស្នើសុំការយល់ព្រមចូលរួម។ អ្នកស្រាវជ្រាវបានផ្តល់ពេលវេលា និងឱកាសគ្រប់គ្រាន់ដល់អ្នកចូលរួមក្នុងការ ស្រាវជ្រាវដែលមានសក្តានុពល ដើម្បីពិចារណាក្នុងការយល់ព្រមចូលរួមដោយអនុញ្ញាតអោយពួកគេថ្លឹងថ្លែងរវាងហានិ ភ័យ និងអត្ថប្រយោជន៍នៃការចូលរួម។ អ្នកស្រាវជ្រាវបានជូនជាដំណឹងដល់អ្នកចូលរួមទាំងអស់គ្នាថារាល់ព័ត៌មានទាំង អស់នឹងត្រូវបានទុកជាការសម្ងាត់។

- ការយល់ព្រមគឺស្ម័គ្រចិត្តគ្មានការបង្ខិតបង្ខំ។ ការយល់ព្រមត្រូវបានធ្វើឡើងដោយពាក្យសំដី និងជាលាយលក្ខណ៍អក្សរ។ ប្រសិនបើអ្នកចូលរួមមិនអាចអាន ឬយល់ទម្រង់នៃការយល់ព្រម អ្នកស្រាវជ្រាវអានវាឱ្យច្បាស់ៗសម្រាប់អ្នកចូលរួមស្តាប់ មុនពេលពួកគេយល់ព្រម ដោយពាក្យសំដី។

- អ្នកចូលរួមស្រាវជ្រាវអាចបញ្ឈប់ការចូលរួមរបស់ពួកគេនៅដំណាក់កាលណាមួយដោយគ្មានបញ្ហាចោទ។

- អ្នកស្រាវជ្រាវបានប្រើការអត់ធ្មត់ និងភាពប៉ិនប្រសព្វក្នុងការធ្វើបទសម្ភាសន៍ ដើម្បីជៀសវាងប៉ះពាល់ផ្លូវចិត្តអ្នកចូលរួម ដែលនាំឱ្យពួកគេផ្តល់ចម្លើយមិនត្រឹមត្រូវ និង/ឬបកស្រាយចម្លើយខុស។

- អ្នកស្រាវជ្រាវបានរក្សាទំនាក់ទំនងជាមួយអ្នកគ្រប់គ្រង និងសហការីស្រាវជ្រាវរបស់ពួកគេ ហើយបានជូនដំណឹងដល់ពួកគេភ្លាមៗអំពីបញ្ហា ឬកាលៈទេសៈណាមួយដែលធ្វើឱ្យមានការភ័ន្តច្រឡំ ឬមិនច្បាស់លាស់។

## 2.2 ការវិភាគទិន្នន័យ

បន្ទាប់ពីប្រមូលទិន្នន័យរួច ក្រុមស្រាវជ្រាវបានជួបប្រជុំគ្នា ដើម្បីបង្រួបបង្រួមទិន្នន័យនិងព័ត៌មានទាំងអស់ ដើម្បីឆ្លើយតបសំណួរស្រាវជ្រាវ និងស្វែងយល់ពីការរកឃើញ។ អ្នកស្រាវជ្រាវមកពីខេត្តបាត់ដំបង និងភ្នំពេញបានមកធ្វើការរួមគ្នា ហើយ GADC បានប្រើវិធីសាស្ត្រស្រាវជ្រាវបែបហ្វេមមីនីសដើម្បីជាជំនួយដល់ក្រុមស្រាវជ្រាវក្នុងការវិភាគពីបញ្ហា និងវិភាគរួមគ្នាជាមួយសហគ្រិនស្ត្រីដែលត្រូវបានបណ្តុះបណ្តាលជាអ្នកស្រាវជ្រាវ។ យើងបានបកស្រាយ និងសម្រួលទិន្នន័យអោយងាយយល់ ស្របពេលគ្នានោះយើងក៏បានឆ្លុះបញ្ចាំងពីឥទ្ធិពលនៃស្ថាប័ន និងបុគ្គល និងសក្តានុពលនៅក្នុងក្រុមស្រាវជ្រាវក្នុងអំឡុងពេលដំណើរការនេះផងដែរ។

ក្នុងអំឡុងពេលនៃការវិភាគ សមាជិកក្រុមបានប្តូរវេនគ្នាដោយប្រើតួនាទីបីផ្សេងគ្នា ដើម្បីយល់កាន់តែច្បាស់ពីការរកឃើញរបស់យើង៖

1. ការបោះជំហានទៅមុខ៖ ការប្រើប្រាស់អំណាចរបស់យើងដើម្បីផ្តល់ធនធាន និងការចូលរួមប្រើប្រាស់ ដល់អង្គការសិទ្ធិស្ត្រី និងធ្វើការរួមចំណែកផ្ទាល់ចំពោះចលនាហ្វេមមីនីស។
2. ឈរជាមួយ៖ ឈរក្នុងសាមគ្គីភាព និងពង្រីកការងាររបស់តួអង្គផ្សេងទៀត។
3. បោះជំហានថយក្រោយ៖ បង្កើតគម្លាត នៅពេលអ្នកផ្សេងទៀតអាចមានសមត្ថភាពដឹកនាំបានប្រសើរជាង។

ដើម្បីបង្កើតការរកឃើញនៃការសិក្សាស្រាវជ្រាវ យើងនឹងប្រើប្រាស់ ឧបករណ៍ 'យេនឌ័រនៅកន្លែងការងារ' ដែលមានបួនជ្រុងសំខាន់ៗ៖



ប្រភព៖ យេនឌ័រនៅកន្លែងការងារ ដែលជាបណ្ដាញចំណេះដឹងស្ត្រីអន្តរជាតិដែលធ្វើការដើម្បីបញ្ចប់ការរើសអើងស្ត្រី និងកសាងវប្បធម៌នៃបរិយាបន្ន។

1. **មនសិការ និងសមត្ថភាពរបស់បុគ្គល** រួមមានចំណេះដឹង ជំនាញ ការយល់ដឹងពីនយោបាយ និងការប្ដេជ្ញាចិត្តក្នុងការផ្លាស់ប្ដូរឆ្ពោះទៅរកសមភាព។

2. **ធនធាន** មានដូចជាសំឡេង សេរីភាពពីអំពើហឹង្សា លទ្ធភាពទទួលបានសេវាសុខភាព និងការអប់រំដែលមានឥទ្ធិពលលើលទ្ធផលយេនឌ័រ។

3. **បទដ្ឋានក្រៅផ្លូវការនិងការអនុវត្តលើការមិនរាប់បញ្ចូល** ដែលរក្សាឬកាត់បន្ថយការរើសអើងនិង/ឬវិសមភាព។

4. **ច្បាប់ និងគោលនយោបាយផ្លូវការ** ដែលបង្កើតភាពមិនរាប់បញ្ចូលក្នុងសង្គមរស់នៅប្រចាំថ្ងៃ។

## 2.3 ការស្រាវជ្រាវលើសកម្មភាព

ទិន្នន័យពីការសិក្សាស្រាវជ្រាវនេះ នឹងមិនត្រឹមតែរួមចំណែកដល់ការស្រាវជ្រាវដែលមានទាក់ទងនឹងបញ្ហាប្រឈមអន្តរប្រសព្វដែលប៉ះពាល់ដល់ការទទួលបានហិរញ្ញវត្ថុ និងការវិនិយោគជាបន្តបន្ទាប់របស់សហគ្រិនស្ត្រី WE ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចធ្វើជាសកម្មភាពក្នុងការដោះស្រាយបញ្ហាផងដែរ។ ការសិក្សានេះផ្ដល់នូវឱកាសឆ្លុះបញ្ចាំងសម្រាប់សហគ្រិនស្ត្រីដើម្បីស្វែងយល់ពីសក្ដានុពលនៅក្នុងបទពិសោធន៍ជីវិតរបស់ពួកគេទាក់ទងនឹងទិដ្ឋភាពផ្សេងៗទាក់ទងនឹងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ សម្រាប់ GADC ការស្រាវជ្រាវនេះបានបន្ថែមតម្លៃដល់ផែនការយុទ្ធសាស្ត្រ 5 ឆ្នាំរបស់អង្គការ ដែលបង្ហាញពីគោលដៅពង្រឹងភាពជាអ្នកដឹកនាំដល់ស្ត្រី និងការពង្រឹងសក្ដានុពលសេដ្ឋកិច្ចរបស់ស្ត្រី ដោយបង្កើនសមត្ថភាពរបស់ពួកគេក្នុងការអភិវឌ្ឍខ្លួន គ្រប់គ្រងធនធាន និងទទួលបានអត្ថប្រយោជន៍ពីធនធានសេដ្ឋកិច្ច។ លើសពីនេះ សម្រាប់ SHE ដែលផ្ដល់កម្មវិធីបណ្ដុះបណ្ដាលផ្លាស់ប្ដូរសមភាពយេនឌ័រ និងវប្បធម៌ វា

នឹងផ្តល់ឱកាសក្នុងការសម្របខ្លួន និងកែលម្អកម្មវិធីគាំទ្រដែលផ្តល់ជូនសហគ្រិនស្ត្រី។ ជាចុងក្រោយ ការសិក្សាស្រាវជ្រាវនេះ នឹងផ្តល់ជាអនុសាសន៍ជាក់ស្តែងសម្រាប់ស្ថាប័នហិរញ្ញវត្ថុ វិនិយោគិន និងរាជរដ្ឋាភិបាល ដែលអាចឱ្យពួកគេពិចារណាលើគោលនយោបាយ និងវិធីសាស្ត្រផ្សេងៗទៀត ដែលអាចកាត់បន្ថយបញ្ហាប្រឈមអន្តរប្រសព្វដែលសហគ្រិនស្ត្រីជួបប្រទះ។

## III. ការរកឃើញពីការស្រាវជ្រាវ

ការរកឃើញសំខាន់ៗដែលបានពិពណ៌នានៅក្នុងផ្នែកនេះ ពោលគឺស្វែងរកការដោះស្រាយបញ្ហាដែលបានលើកឡើងជាសំណួរស្រាវជ្រាវបឋមចំនួនបីរបស់យើង (ពន្យល់ខាងលើ)៖

- តើអ្វីជាបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វដែលជះឥទ្ធិពលដល់សហគ្រិនស្រីខ្នាតតូច និងមធ្យម (WSMEs) ក្នុងការទទួលបានសេវារបស់ស្ថាប័នហិរញ្ញវត្ថុ (ផលិតផល សេវាកម្ម ការវិនិយោគ)?
- តើមានក្របខ័ណ្ឌយេនឌ័រអ្វីខ្លះដែលស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់ដើម្បីគាំទ្រដល់សហគ្រិនស្ត្រីខ្នាតតូច និងមធ្យម (WSMEs) ដើម្បីអភិវឌ្ឍ និងឆ្លើយតបទៅនឹងអាជីវកម្មរបស់ពួកគេ និងធ្វើឱ្យអាជីវកម្មរបស់ពួកគេប្រសើរឡើង?
- តើស្ថាប័នហិរញ្ញវត្ថុគួរធ្វើដូចម្តេចដើម្បីបញ្ឈប់នូវផលប៉ះពាល់នៃផ្នែកដែលជាបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វរបស់សហគ្រិនស្ត្រីខ្នាតតូច និងមធ្យម (WSMEs)?

### 3.1 បញ្ហាប្រឈមទូទៅដែលប៉ះពាល់ដល់ WEs

មានបញ្ហាប្រឈមទូទៅចំនួនបួនដែលប៉ះពាល់ដល់សិទ្ធិទទួលបានហិរញ្ញវត្ថុរបស់សហគ្រិនស្ត្រី៖

1. ការទទួលបានព័ត៌មាន
2. តម្រូវការទ្រព្យបញ្ចាំ
3. អត្រាការប្រាក់ខ្ពស់ និង
4. ដំណើរការដាក់ពាក្យសុំកម្ចីស្មុគស្មាញ។

#### 3.1.1 សិទ្ធិទទួលបានព័ត៌មាន

ទាក់ទងនឹងការទទួលបានព័ត៌មានមានលទ្ធផលចម្រុះ។ សហគ្រិនស្ត្រី WEs ភាគច្រើនបានសម្តែងការស្ទាក់ស្ទើរក្នុងការស្នើសុំប្រាក់កម្ចីដោយសារតែការភ័យខ្លាចមិនអាចសងត្រលប់វិញបាន។ សហគ្រិនមួយចំនួនបានរាយការណ៍ថាទទួលបានការគាំទ្រច្រើនពីស្ថាប័នហិរញ្ញវត្ថុ FIs ខណៈពេលដែលអ្នកផ្សេងទៀតមានអារម្មណ៍ថាពួកគេដូចជាមិនត្រូវបានផ្តល់ព័ត៌មានគ្រប់គ្រាន់។

បទពិសោធន៍វិជ្ជមានមួយចំនួនដែលទទួលបានពីស្ថានប័នហិរញ្ញវត្ថុ FIs រួមមានការផ្តល់ព័ត៌មានច្បាស់លាស់អំពីផលិតផល និងសេវាកម្មដែលមានរៀបរាប់ដូចខាងក្រោម៖

*"នៅពេលខ្ញុំទៅស្នើសុំប្រាក់កម្ចីពីធនាគារ ពួកគេបានពន្យល់ខ្ញុំយ៉ាងច្បាស់អំពីព័ត៌មាននៃប្រាក់កម្ចី"* - WE FGD នៅខេត្តបាត់ដំបង។

*"CO បានមកសួរខ្ញុំថាតើខ្ញុំត្រូវការប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្មរបស់ខ្ញុំឬអត់ ហើយបានផ្តល់ព័ត៌មានខ្លះៗអំពីប្រាក់កម្ចី និងនីតិវិធី"* - WE IDI នៅភ្នំពេញ។

លើសពីការផ្តល់ព័ត៌មាន បុគ្គលិកស្ថាប័នហិរញ្ញវត្ថុ FI មួយចំនួនក៏បានផ្តល់ការគាំទ្របន្ថែមក្នុងការគណនាការប្រាក់កម្ចីដែលសមស្រប រួមទាំងព័ត៌មានច្បាស់លាស់អំពីកាលវិភាគសងត្រលប់៖

*"CO បានពិគ្រោះយោបល់ជាមួយខ្ញុំអំពីចំណូលប្រចាំខែ និងការចំណាយរបស់ខ្ញុំ ដើម្បីដឹងថាតើខ្ញុំមានលទ្ធភាពសងដែរឬទេ។ វាផ្តល់អត្ថប្រយោជន៍ទាំងសងខាងសម្រាប់ខ្ញុំ និងពួកគេ» - WE IDI នៅភ្នំពេញ។*

ការរកឃើញសំខាន់មួយគឺសហគ្រិនស្ត្រីខ្វះការយល់ដឹង ពីតួនាទីរបស់ការិយាល័យឥណទានកម្ពុជា (CBC) ដែលតួនាទីរបស់ពួកគេគឺផ្តល់ព័ត៌មានហិរញ្ញវត្ថុ ជំនួយលើការវិភាគ និងផ្តល់របាយការណ៍ឥណទាន ដែលតាមដានប្រាក់កម្ចីសកម្ម និងកម្ចីដែលបានទូទាត់រួច ដែលមានឥទ្ធិពលលើពិន្ទុឥណទានរបស់អ្នកខ្ចី។

*"ដោយសារខ្ញុំមិនមានពិន្ទុឥណទានល្អពីអំឡុងពេលកូវីដ១៩ ខ្ញុំបានខកខានការទូទាត់ប្រាក់កម្ចី ឈ្មោះរបស់ខ្ញុំស្ថិតនៅក្នុងបញ្ជីរបស់ CBC ទោះបីជានៅពេលនោះ រដ្ឋាភិបាលបានអនុញ្ញាតឱ្យមានការពន្យារពេលក្នុងការទូទាត់ការសងត្រលប់ក៏ដោយ។ វាធ្វើឱ្យមានការលំបាកក្នុងការទទួលបានកម្ចីដើម្បីពង្រីកអាជីវកម្មរបស់ខ្ញុំ»* - WE IDI នៅភ្នំពេញ។

### 3.1.2 ភាពស្មុគស្មាញនៃដំណើរការនៃការស្នើសុំកម្ចី

សហគ្រិនស្ត្រី WEs បានកត់សម្គាល់ថាតម្រូវការរបស់ស្ថាប័នហិរញ្ញវត្ថុ FIs គឺជាបញ្ហាប្រឈមដ៏ធំ នៅពេលដែលពួកគេព្យាយាមដាក់ពាក្យសុំប្រាក់កម្ចី។ សហគ្រិនស្ត្រី WEs ជាច្រើនបាននិយាយថា ពួកគេមានការលំបាកក្នុងការប្រមូលឯកសារដែលជាតម្រូវការ សូម្បីតែពួកគេដឹងថាឯកសារណាខ្លះដែលត្រូវការក៏ដោយ។

បុគ្គលិកស្ថាប័នហិរញ្ញវត្ថុ FIs មួយចំនួនបានគាំទ្រយ៉ាងសកម្មចំពោះសហគ្រិនស្ត្រី WEs ក្នុងការដំណើរឯកសារស្នើ ដូច្នេះពួកគេអាចទទួលបានប្រាក់កម្ចី ដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកដែលធ្លាប់ទទួលបានប្រាក់កម្ចីពីមុន ឬអាជីវកម្មរបស់ពួកគេបានចុះបញ្ជី៖

*"ដោយសារខ្ញុំជាអតិថិជនពីមុន ខ្ញុំមានប្រវត្តិឥណទានល្អ។ ដូច្នេះភ្នាក់ងារបានជួយសម្របសម្រួលជាមួយឯកសារឲ្យបានលឿនជាងមុន និងទទួលបានកម្ចីធំជាងមុន»* - WE FGD នៅបាត់ដំបង។

*"CO បាននិយាយមកខ្ញុំថា គាត់អាចជួយរៀបចំឯកសារអោយខ្ញុំក្នុងការស្នើសុំប្រាក់កម្ចី។ ខ្ញុំគ្រាន់តែយកឯកសារ៣ប្រភេទ (អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងប៉ាតង់អាជីវកម្ម) ទៅឲ្យគាត់ ហើយគាត់នឹងចាត់ចែងវាឲ្យខ្ញុំក្នុងពេលបីថ្ងៃ»*- WE IDI នៅបាត់ដំបង។

ទោះជាយ៉ាងណាក៏ដោយ នេះមិនមែនជាករណីសម្រាប់សហគ្រិនស្ត្រី WEs ភាគច្រើនដែលបានសម្ភាសន៍នោះទេ។ សហគ្រិនស្ត្រី WEs បានចែករំលែកថាដំណើរការស្នើសុំកម្ចីស្មុគស្មាញ រារាំងពួកគេពីការទទួលបានការប្រើប្រាស់ហិរញ្ញវត្ថុពេញលេញ៖

*«វាមិនងាយស្រួលក្នុងការទទួលបានកម្ចីទេ ព្រោះមានតម្រូវការឯកសារច្រើន ហើយវាមានភាពស្មុគស្មាញ»* - WE IDI នៅភ្នំពេញ។

អ្នកផ្សេងទៀតបាននិយាយអំពីបញ្ហាប្រឈមក្នុងការរៀបចំឯកសារ ជាពិសេសប្រសិនបើអាជីវកម្មរបស់ពួកគេមិនត្រូវបានចុះបញ្ជីជាផ្លូវការ៖

*"ខ្ញុំចង់ទទួលបានប្រាក់កម្ចី ប៉ុន្តែខ្ញុំមិនមានឯកសារគ្រប់គ្រាន់ទេ"* - WE IDI នៅបាត់ដំបង។

### 3.1.3 តម្រូវការទ្រព្យបញ្ចាំ

ទ្រព្យបញ្ចាំបង្កបញ្ហាប្រឈមយ៉ាងសំខាន់ចំពោះសហគ្រិនស្ត្រី WEs ជាច្រើន។ ដោយសារអាជីវកម្មភាគច្រើននៅក្នុងការសិក្សានេះគឺមិនផ្លូវការ និងមិនទាន់បានចុះបញ្ជី ពួកគេទាមទារការប្រើប្រាស់ដី ឬអ្នកធានា ដើម្បីអាចទទួលបានប្រាក់កម្ចី។

សហគ្រិនស្ត្រី WEs ជាច្រើនបានចែករំលែកពីរបៀបដែលស្ថាប័នហិរញ្ញវត្ថុ FIs អាចផ្តល់ការគាំទ្រ និងភាពងាយស្រួល ដល់អ្នកដែលមានវត្ថុបញ្ចាំ និងប្រាក់ចំណូល៖

*"ខ្ញុំមិនមានអារម្មណ៍ត្រូវបានគេរើសអើងទេ ដរាបណាខ្ញុំមានទ្រព្យបញ្ចាំ និងប្រាក់ចំណូលគ្រប់គ្រាន់។ ពួកគេនឹងជួយខ្ញុំក្នុងការដំណើរការឯកសារ"* - WE IDI នៅភ្នំពេញ។

បញ្ហាប្រឈមបន្ថែមរួមមានតម្រូវការទ្រព្យបញ្ចាំ សម្រាប់សហគ្រិនស្ត្រីមួយចំនួនដែលគ្មានលំនៅដ្ឋានអចិន្ត្រៃយ៍ ប៉ះពាល់ដល់លទ្ធភាពទទួលបានប្រាក់កម្ចី៖

*"ការលំបាកគឺខ្ញុំមិនមានទ្រព្យបញ្ចាំណាមួយដើម្បីទទួលបានប្រាក់កម្ចី។ ខ្ញុំរស់នៅផ្ទះជួល និងជួលកន្លែងធ្វើអាជីវកម្ម»* - WE IDI នៅភ្នំពេញ។

មានបញ្ហាប្រឈមច្រើនទៀតសម្រាប់ស្ត្រីដែលនៅលីវ ជាស្ត្រីមេម៉ាយ និងមនុស្សចាស់ (54+ ឆ្នាំ)៖

*"ក្នុងនាមជាស្ត្រីនៅលីវ ប្រសិនបើខ្ញុំគ្មានអ្នកធានា ខ្ញុំមិនអាចខ្ចីប្រាក់បានទេ មានតែសម្រេចចិត្តខ្ចីប្រាក់ពីបុគ្គលឯកជននៅក្នុងភូមិរបស់ខ្ញុំ ប៉ុន្តែគេមានអត្រាការប្រាក់ខ្ពស់»* - WE FGD ខេត្តបាត់ដំបង។

*"ខ្ញុំមិនមានមុខមាត់ក្នុងសង្គមទេ ហើយខ្ញុំនៅលីវ ខ្ញុំមិនមានវត្ថុបញ្ចាំទេ ដូច្នេះខ្ញុំមិនហ៊ានស្នើសុំប្រាក់កម្ចីទេ"* - WE IDI នៅបាត់ដំបង។

### 3.1.4 អត្រាការប្រាក់ខ្ពស់

សហគ្រិនស្ត្រី WEs បានលើកឡើងថាអត្រាការប្រាក់ខ្ពស់ពេក។ ទោះបីជាមានអត្រាប្រសើរជាងមុន ដែលបានផ្តល់ដោយធនាគារ SME (5.5%) ក៏ដោយ សិទ្ធិដាក់ពាក្យបានគឺសម្រាប់តែសហគ្រិនដែលបានចុះបញ្ជីអាជីវកម្មរបស់ពួកគេជាមួយក្រសួងពាណិជ្ជកម្មហើយប៉ុណ្ណោះ។

អត្រាការប្រាក់ខ្ពស់ គឺជាបញ្ហាប្រឈមដ៏សំខាន់សម្រាប់សហគ្រិនស្ត្រី WEs ជាច្រើនក្នុងការវិនិយោគក្នុងអាជីវកម្មរបស់ពួកគេ៖

*"ខ្ញុំគិតថាអត្រាការប្រាក់គឺខ្ពស់ណាស់សម្រាប់ការវិនិយោគលើអាជីវកម្ម។ វាមិនមានតុល្យភាពជាមួយនឹងឱកាសរកប្រាក់ចំណូលទេ ពីព្រោះការចំណាយកាន់តែកើនឡើងជារៀងរាល់ថ្ងៃ"* - WE IDI នៅភ្នំពេញ។

*"ខ្ញុំមិនហ៊ានខ្ចីលុយគេទេ ព្រោះខ្ញុំគ្មានសមត្ថភាពសងវិញ អត្រាការប្រាក់ខ្ពស់ ហើយគេនឹងដាក់ពិន័យយើងពេលយើងបន្ថែមថវិការទៅក្នុងអាជីវកម្ម។ ខ្ញុំមិនមានកំលាំងប្រឹងប្រែងដើម្បីធ្វើវាទេ។ "* - WE IDI នៅភ្នំពេញ។

សហគ្រិនស្ត្រីWEs បានចែករំលែកថា ទំនាក់ទំនងរវាងអត្រាការប្រាក់និងទ្រព្យបញ្ចាំ ដោយបង្ហាញពីរបៀបដែលបញ្ហាប្រឈមទាំងនេះបូកបញ្ចូលគ្នាហើយបង្កើតជាបញ្ហាប្រឈមបន្ថែមទៀត៖

*"ខ្ញុំមិនមានទ្រព្យសម្បត្តិទេ ហាងសាឡូនសង់លើដីបងថ្លៃខ្ញុំ ពេលខ្ញុំទៅសុំខ្ចីពីស្ថាប័នហិរញ្ញវត្ថុ FIs គេទាមទារអត្រាការប្រាក់ខ្ពស់ណាស់ បើខ្ញុំគ្មានវត្ថុបញ្ចាំ"* - WE IDI នៅបាត់ដំបង។

ទោះជាយ៉ាងណាក៏ដោយសហគ្រិនស្ត្រី WEs បានចែករំលែកការខិតខំប្រឹងប្រែងជាវិជ្ជមានពីស្ថាប័នហិរញ្ញវត្ថុ FIs ជាពិសេសក្នុងអំឡុងពេលជំងឺរាតត្បាត ដែលជាការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជាទៅកាន់ស្ថាប័នហិរញ្ញវត្ថុ FIs ផងដែរ៖

*"បន្ទាប់ពីកូវីដ១៩ វាពិបាកសម្រាប់ខ្ញុំក្នុងការសងប្រាក់កម្ចី ដូច្នេះពួកគេបានអនុញ្ញាតពន្យាប៉ុន្មានថ្ងៃសម្រាប់ការសងត្រឡប់ជារៀងរាល់ខែសម្រាប់ខ្ញុំ ប៉ុន្តែមិនអោយឆ្លងដល់ខែថ្មីនោះទេ"* - WE IDI នៅក្នុងខេត្តបាត់ដំបង។

## 3.2 បញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វ

បន្ទាប់មកទៀតនេះ យើងស្វែងយល់ពីអន្តរប្រសព្វ និងរបៀបដែលវាប៉ះពាល់ដល់លទ្ធភាពទទួលបានហិរញ្ញវត្ថុរបស់សហគ្រិនស្ត្រី។

### 3.2.1 ស្ត្រីដែលមានពិការភាព

សហគ្រិនស្ត្រីមួយចំនួននៅក្នុងការសិក្សាស្រាវជ្រាវបានពិពណ៌នាអំពីបទពិសោធន៍វិជ្ជមាន ទោះបីជាមានពិការភាពក៏ដោយ៖

*"ខ្ញុំជាជនពិការ ហើយពួកគេផ្តល់លទ្ធភាពឲ្យខ្ញុំខ្ចីប្រាក់ព្រោះខ្ញុំអាចសងត្រឡប់បាន"* ។ - WE FGD នៅបាត់ដំបង។

ក្នុងការដោះស្រាយអន្តរប្រសព្វ ក៏ដូចជាការរួមបញ្ចូលសមភាពយេនឌ័រ ទិន្នន័យរបស់យើងបង្ហាញថាមានគំនិតផ្តួចផ្តើមមួយចំនួនពីស្ថាប័នហិរញ្ញវត្ថុ FIs ដើម្បីផ្តល់សិទ្ធិអំណាចដល់សហគ្រិនស្ត្រី WEs ជាពិសេសសហគ្រិនស្ត្រី WEs ដែលមានពិការភាពក្នុងការធ្វើឱ្យអគាររបស់ស្ថាប័នពួកគេអាចចូលប្រើប្រាស់បានកាន់តែច្រើន៖

*"ខ្ញុំបានឃើញធនាគារមានជម្រាលផ្លូវ និងជណ្តើរយន្តសម្រាប់ជនពិការចូលប្រើប្រាស់បាន»* - WE IDI នៅភ្នំពេញ។

ទោះជាយ៉ាងណាក៏ដោយ ភាគច្រើន ស្ត្រីមានពិការភាពប្រឈមមុខនឹងបញ្ហាជាច្រើនក្នុងការទទួលបានផលិតផល និសេវាកម្មហិរញ្ញវត្ថុ៖

*"ខ្ញុំពិតជាចង់ទទួលបានប្រាក់កម្ចី ប៉ុន្តែខ្ញុំមិនមានអ្នកធានាទេ។ ខ្ញុំពិការ ដូច្នេះគ្មានអ្នកណាអោយខ្ញុំខ្ចីលុយទេ»* - WE IDI នៅក្នុងខេត្តបាត់ដំបង។

អ្នកចូលរួមម្នាក់ទៀតបានចែករំលែកពីអន្តរប្រសព្វនៃទំហំប្រាក់កម្ចីដែលបានស្នើសុំ៖

*"ក្នុងនាមខ្ញុំជាជនពិការ ខ្ញុំចង់ដកប្រាក់កម្ចីក្នុងបរិមាណដែលខ្ញុំត្រូវការពីធនាគារ ជាមួយនឹងទ្រព្យបញ្ចាំដែលមានតម្លៃខ្ពស់ ប៉ុន្តែស្ថាប័នហិរញ្ញវត្ថុ (FI) មិនបានផ្តល់ឱ្យខ្ញុំនូវទំហំកម្ចីដែលខ្ញុំបានស្នើសុំទេ ដោយសារពួកគេគិតថាដោយសារតែពិការភាពរបស់ខ្ញុំ សមត្ថភាពក្នុងការសងត្រលប់របស់ខ្ញុំមានកំណត់"* - WE FGD នៅភ្នំពេញ។

សហគ្រិនស្ត្រីម្នាក់បានបង្ហាញពីអន្តរប្រសព្វនៃអាយុ និងពិការភាព ដែលបណ្តាលឱ្យមានការរើសអើងហួសហេតុ៖

*"ខ្ញុំចាស់ហើយក៏ពិការផងដែរ។ ពេលគេឃើញខ្ញុំ គេធ្វើពុតជាមើលមិនឃើញ ហើយបែរមុខចេញ ដោយធ្វើពុតជាមិនឃើញខ្ញុំ»* - WE FGD នៅក្នុងខេត្តបាត់ដំបង។

សហគ្រិនស្ត្រី WEs ក៏បានចែករំលែកផងដែរនូវផលប៉ះពាល់ដែលការរើសអើងអាចប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់ពួកគេ៖

*"ពេលខ្លះ ខ្ញុំមានអារម្មណ៍ក្រៀមក្រំ ខកចិត្តនឹងខ្លួនឯង នៅពេលដែលស្ថាប័នហិរញ្ញវត្ថុ FIs មើលរំលងសមត្ថភាពរបស់ខ្ញុំ"* - WE IDI នៅបាត់ដំបង។

### 3.2.2 ស្ត្រីដែលចំនេះដឹងនៅមានកម្រិត

តាមរយៈ IDIs យើងបានដឹងថាសហគ្រិនស្ត្រី WEs មួយចំនួនពិបាកក្នុងការទទួលបានប្រាក់កម្ចីដោយសារតែការអប់រំនៅមានកម្រិត។ ជាឧទាហរណ៍ សម្រាប់សហគ្រិនស្ត្រី WEs ដែលមិនចេះអក្សរ វាកាន់តែពិបាកក្នុងការស្វែងយល់អំពីសេវាកម្មហិរញ្ញវត្ថុដែលមានស្រាប់ ទោះជាមានការគាំទ្រដែលស្ថាប័នហិរញ្ញវត្ថុ FIS មួយចំនួនផ្តល់ជូនដើម្បីជួយសម្រួលដល់ការទទួលបានផលិតផលនិងសេវាកម្មហិរញ្ញវត្ថុក៏ដោយ៖

*"ខ្ញុំមិនចេះអាន ឬសរសេរទេ ដូច្នេះវាពិបាកសម្រាប់ខ្ញុំក្នុងការទទួលបានព័ត៌មានអំពីប្រាក់កម្ចី"* - WE FGD នៅខេត្តបាត់ដំបង។

សហគ្រិនស្ត្រី WE មួយចំនួនបានអះអាងថា នេះគឺប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់ពួកគេ៖

*"ពេលខ្លះ ខ្ញុំមានអារម្មណ៍ក្រៀមក្រំ និងខកចិត្តក្នុងខ្លួនខ្ញុំ នៅពេលដែល FIs មើលរំលងសមត្ថភាពរបស់ខ្ញុំ"* - WE IDI នៅខេត្តបាត់ដំបង ។

### 3.2.3 ស្ត្រីដែលមានទំនោរផ្លូវភេទ និងការបង្ហាញអត្តសញ្ញាណយេនឌ័រចម្រុះ

គ្រួសារ LGBTQIA+ ប្រឈមមុខនឹងបញ្ហាជាពិសេស ដោយសារអាពាហ៍ពិពាហ៍ភេទដូចគ្នាមិនទាន់ស្របច្បាប់ក្នុងប្រទេសកម្ពុជា ដូច្នេះហើយគូស្នេហ៍ភេទដូចគ្នាមិនអាចមានទ្រព្យបញ្ចាំរួមគ្នាក្នុងទម្រង់ជាកម្មសិទ្ធិរួមបានទេ។

នៅក្នុងការសម្ភាសន៍ស៊ីជម្រៅ IDI ជាមួយ LGBTQIA+ សហគ្រិនស្ត្រី WE អ្នកចូលរួមសម្ភាសន៍បានពន្យល់ពីការលំបាកដែលពួកគេបានជួបប្រទះ នៅពេលដែលពួកគេព្យាយាមដាក់នូវទ្រព្យសម្បត្តិ ដែលពួកគេបានសន្សំរួមគ្នាជាមួយដៃគូ ដើម្បីប្រើប្រាស់ជាទ្រព្យបញ្ចាំសម្រាប់ពង្រីកអាជីវកម្ម៖

*"ពីមុនខ្ញុំអាចទទួលបានប្រាក់កម្ចីដើម្បីពង្រីកអាជីវកម្មរបស់ខ្ញុំដោយខ្លួនឯង ប៉ុន្តែដោយសារតែមានបញ្ហាជាមួយគណនីធនាគាររបស់ខ្ញុំ ប៉ះពាល់ដល់ប្រវត្តិឥណទាននៅលើ CBC របស់ខ្ញុំ ខ្ញុំកំពុងគិតថាមានទ្រព្យសម្បត្តិរួមជាវត្ថុបញ្ចាំ ប៉ុន្តែយើងមិនអាចដាក់បានទេ ដោយសារគ្មានឯកសារផ្លូវច្បាប់ជាផ្លូវការដែលយើងអាចធ្វើដើម្បីផ្ទៀងផ្ទាត់ថាយើងជាប្តីប្រពន្ធ និងជាម្ចាស់អចលនទ្រព្យជាមួយគ្នា»* - WE IDI នៅភ្នំពេញ។

### 3.2.4 ស្ត្រីដែលមានសមាសភាពគ្រួសារមិនតាមប្រពៃណី

យើងបានឮនៅក្នុង IDIs និង FGDs ថាសហគ្រិនស្ត្រី WEs ប្រឈមនឹងការរើសអើងនៅពេលព្យាយាមទទួលបានប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ FIs នៅពេលដែលពួកគេមិនមានសមាសភាពគ្រួសារធម្មតា។

ម្នាក់ទៀតបានចែករំលែកពីរបៀបដែលមិនមានដៃគូជាអ្នកធានា ជះឥទ្ធិពលអវិជ្ជមានដល់ការទទួលបានផលិតផលនិងសេវាហិរញ្ញវត្ថុ៖

*"ខ្ញុំចង់បានកម្ចី ប៉ុន្តែខ្ញុំមិនអាចទទួលបាន ដោយសារតម្រូវការរបស់ពួកគេ ដែលតម្រូវឱ្យខ្ញុំមានអ្នកណាម្នាក់ចូលរួមកម្ចីជាមួយខ្ញុំ។ ពួកគេបាននិយាយថា ប្រសិនបើខ្ញុំជាស្ត្រីមេម៉ាយ ម្តាយរបស់ខ្ញុំអាចចូលរួមជាមួយខ្ញុំក្នុងការទទួលបានប្រាក់កម្ចី ប៉ុន្តែខ្ញុំមិនចង់ឱ្យរំខានគាត់នោះទេ។ ខ្ញុំចង់រកប្រាក់ដោយខ្លួនឯង ហើយសងវាដោយខ្លួនឯង»* - WE IDI នៅបាត់ដំបង។

*"តាំងពីប្តីខ្ញុំស្លាប់ ខ្ញុំមិនអាចខ្ចីលុយបានទេ ព្រោះគ្មានអ្នកធានា"* - WE IDI in Battambang.

នេះជាលទ្ធផលស្ត្រីគ្មានជម្រើសអ្វីក្រៅពីខ្ចីប្រាក់ក្រៅផ្លូវការដោយមានលក្ខខណ្ឌការប្រាក់ខ្ពស់នោះទេ៖

*"ក្នុងនាមជាស្ត្រីនៅលីវ ប្រសិនបើខ្ញុំមិនមានអ្នកធានា ខ្ញុំមិនអាចទទួលបានប្រាក់កម្ចីទេ ដូច្នេះខ្ញុំសម្រេចចិត្តខ្ចីលុយពីបុគ្គលឯកជននៅក្នុងភូមិរបស់ខ្ញុំ ប៉ុន្តែកម្ចីរបស់ពួកគេអត្រាការប្រាក់ខ្ពស់ណាស់»* - WE FGD នៅបាត់ដំបង។

ផលប៉ះពាល់យ៉ាងច្បាស់លើលទ្ធភាពទទួលបានហិរញ្ញវត្ថុត្រូវបានបង្ហាញដោយសហគ្រិនស្ត្រី WEs ទោះបីជាពួកគេមានលទ្ធភាពស្របតាមតម្រូវការលក្ខណៈវិនិច្ឆ័យប្រាក់កម្ចីក៏ដោយ៖

*"ខ្ញុំមានអាជីវកម្ម ផ្ទះ និងវត្ថុបញ្ចាំដើម្បីដាក់តម្កល់យកកម្ចី ហេតុអ្វីបានជាខ្ញុំមិនអាចទទួលបានប្រាក់កម្ចីដោយខ្លួនឯង ហើយហេតុអ្វីបានជាពួកគេតម្រូវឱ្យនរណាម្នាក់ចូលរួមជាមួយខ្ញុំក្នុងការខ្ចីប្រាក់កម្ចី?"* - WE IDI នៅបាត់ដំបង។

*"ខ្ញុំមិនមានមុខមាត់ក្នុងសង្គមទេ ហើយខ្ញុំនៅលីវ។ ខ្ញុំមិនមានវត្ថុបញ្ចាំទេ ដូច្នេះខ្ញុំមិនហ៊ានស្នើសុំកម្ចីនោះទេ»* - WE IDI នៅបាត់ដំបង។

### 3.2.5 ស្ត្រីដែលគោរពសាសនាផ្សេងៗគ្នា

សហគ្រិនស្ត្រី WEs ដែលកាន់សាសនាឥស្លាមមានកម្រិតក្នុងការទទួលបានប្រាក់កម្ចីដោយសារតែច្បាប់នៃសាសនារបស់ពួកគេ។ អ្នកកាន់សាសនាឥស្លាមម្នាក់ដែលយើងបានសម្ភាសន៍បានពន្យល់ថា វាជាអំពើបាបក្នុងការខ្ចីប្រាក់ពីស្ថាប័ន FIs។ គ្មានសហគ្រិនស្ត្រីកាន់សាសនាឥស្លាម WE ដែលចូលរួមក្នុងការសម្ភាសន៍បានដឹងពីស្ថាប័នហិរញ្ញវត្ថុ FIs ណាមួយនៅក្នុងប្រទេសកម្ពុជា ដែលផ្តល់ហិរញ្ញប្បទានក្នុងលក្ខខ័ណ្ឌដែលមិនបំពានច្បាប់ Sharia នោះទេ។ ផ្អែកលើការស្រាវជ្រាវរបស់យើង ទោះបីជាមានស្ថាប័នហិរញ្ញវត្ថុ FIs មួយចំនួនដែលមានប្រភពមកពីប្រទេសមូស្លីមភាគច្រើនដែលបានបង្កើតសាខានៅក្នុងប្រទេសកម្ពុជាក៏ដោយ ស្ថាប័នទាំងនេះមិនបានផ្តល់ជូននូវផលិតផលហិរញ្ញវត្ថុដែលអនុលោមតាម Sharia នោះទេ។

ដោយសារសហគ្រិនស្ត្រី WEs មូស្លីមមិនអាចទទួលបានហិរញ្ញប្បទានពីស្ថាប័នហិរញ្ញវត្ថុ FIs នៅក្នុងប្រទេសកម្ពុជា ពួកគេតែងតែងាកទៅរកមិត្តភ័ក្តិ និងក្រុមគ្រួសារសម្រាប់កម្ចីខ្នាតតូច ដែលគ្មានការប្រាក់។

*"ប្រសិនបើស្ថាប័នហិរញ្ញវត្ថុ FIs ផ្តល់ឱ្យខ្ញុំនូវកញ្ចប់មួយសម្រាប់ការវិនិយោគអាជីវកម្មរបស់ខ្ញុំដោយគ្មានអត្រាការប្រាក់ ខ្ញុំនឹងយកវា។ ប៉ុន្តែប្រសិនបើវាមកជាមួយនឹងអត្រាការប្រាក់ វាផ្ទុយនឹងច្បាប់របស់មូស្លីម។ ជាធម្មតាខ្ញុំខ្ចីលុយពីសមាជិកគ្រួសារជំនួសវិញគ្រប់ពេលដែលខ្ញុំត្រូវការលុយ ក៏ដូចជាដោះស្រាយបញ្ហាប្រឈមក្នុងអាជីវកម្មរបស់ខ្ញុំនៅពេលវាធ្លាក់ចុះ»* - WE IDI នៅភ្នំពេញ។

# IV. យេនឌ័រនៅកន្លែងការងារ

ការសិក្សារបស់យើងបានព្យាយាមឆ្លើយសំណួរស្រាវជ្រាវសំខាន់ៗចំនួនបី៖

- តើអ្វីជាបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វដែលជះឥទ្ធិពលដល់សហគ្រិនស្រីខ្នាតតូច និងមធ្យម (WSMEs) ក្នុងការទទួលបានសេវារបស់ស្ថាប័នហិរញ្ញវត្ថុ (ផលិតផល សេវាកម្ម ការវិនិយោគ)?

- តើមានក្របខ័ណ្ឌយេនឌ័រអ្វីខ្លះដែលស្ថាប័នហិរញ្ញវត្ថុប្រើប្រាស់ដើម្បីគាំទ្រដល់សហគ្រិនស្ត្រីខ្នាតតូច និងមធ្យម (WSMEs) ដើម្បីអភិវឌ្ឍ និងឆ្លើយតបទៅនឹងអាជីវកម្មរបស់ពួកគេ និងធ្វើឱ្យអាជីវកម្មរបស់ពួកគេប្រសើរឡើង?

- តើស្ថាប័នហិរញ្ញវត្ថុគួរធ្វើដូចម្តេចដើម្បីបញ្ឈប់នូវផលប៉ះពាល់នៃផ្នែកដែលជាបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វរបស់សហគ្រិនស្ត្រីខ្នាតតូច និងមធ្យម (WSMEs)?

ផ្នែកទី 3.2 នៃការរកឃើញរបស់យើងខាងលើបានស្វែងយល់ពីសំណួរស្រាវជ្រាវដំបូង។ សំណួរស្រាវជ្រាវទីពីរ និងទីបីត្រូវបានពិភាក្សានៅក្នុងផ្នែកនេះ។ យើងបានជ្រើសរើសក្របខណ្ឌយេនឌ័រនៅកន្លែងការងារ ដើម្បីរៀបចំផ្នែកនេះ ព្រោះវាស្វែងយល់ពីភាពមិនផ្លូវការ បុគ្គលផ្លូវការ និងសក្តានុពលថាមពលជាប្រព័ន្ធសំខាន់ៗដែលមាន។ ខាងក្រោមនេះ យើងប្រើជ្រុងនីមួយៗក្នុងការស្វែងយល់ ដែលយើងអាចទាញចេញជាការរកឃើញនៃការសិក្សានេះ និងយល់កាន់តែច្បាស់អំពីបទពិសោធន៍របស់ WE ជាមួយផលិតផល និងសេវាកម្មរបស់ FIs ដោយផ្តោតជាពិសេសទៅលើផលប៉ះពាល់អន្តរប្រសព្វ។




ប្រភព៖ យេនឌ័រនៅកន្លែងការងារ ដែលជាបណ្តាញចំណេះដឹងស្ត្រីអន្តរជាតិដែលធ្វើការដើម្បីបញ្ចប់ការរើសអើងប្រឆាំងនឹងស្ត្រី និងកសាងវប្បធម៌នៃការដាក់បញ្ចូល។

## ជ្រុងទី 1: សមត្ថភាពដឹងដែលមានវិចារណញ្ញាណ

ជ្រុងទីមួយមើលលើចំណេះដឹង ជំនាញ និងមនសិការនយោបាយ។

ដើម្បីឱ្យសហគ្រិនស្ត្រី WEs មានចំណេះដឹងដែលពួកគេត្រូវការដើម្បីចូលប្រើផលិតផល និងសេវាកម្មពីស្ថាប័នហិរញ្ញវត្ថុ FIs បាន សម្ភារៈ និងវិធីសាស្ត្រដែលប្រើដើម្បីផ្តល់ចំណេះដឹងនេះត្រូវតែមានលក្ខណៈសមស្របតាមបរិបទ និងអាចចូលដំណើរការឬប្រើប្រាស់បាន ដោយគិតគូរពីអន្តរប្រសព្វ។ ជាឧទាហរណ៍សហគ្រិនស្ត្រី WEs មួយចំនួនទទួលបានការអប់រំតិចតួចឬមិនបានទទួលការអប់រំជាផ្លូវការឡើយ ដូច្នេះពួកគេត្រូវការការពិគ្រោះយោបល់ដោយពាក្យសំដីជំនួសឱ្យឯកសារជាអក្សរ ឬពួកគេអាចត្រូវការទម្រង់នៃការចែកចាយព័ត៌មានផ្សេងទៀតដូចជារូបភាព ឬវីដេអូ។

*"ស្ថាប័នហិរញ្ញវត្ថុ FIs គួរតែផ្តល់ការប្រឹក្សា និងការណែនាំកាន់តែច្បាស់អំពីផលិតផលហិរញ្ញវត្ថុដល់អតិថិជនមុនពេលពួកគេធ្វើការសម្រេចចិត្តដើម្បីទទួលបានប្រាក់កម្ចី"* - WE IDI នៅភ្នំពេញ។

ទាក់ទងនឹងជំនាញ សហគ្រិនស្ត្រី WEs ស្នើសុំឱ្យស្ថាប័នហិរញ្ញវត្ថុ FIs ផ្តល់ការបណ្តុះបណ្តាលអំពីរបៀបកត់ត្រា និងគ្រប់គ្រងប្រាក់ចំណូល ចំណាយ និងធ្វើផែនការអាជីវកម្មត្រឹមត្រូវមុន និងក្រោយការស្នើសុំប្រាក់កម្ចី ខណៈដែលអ្នកខ្លះសុំជំនួយពីរបៀបស្នើសុំកម្ចីអោយជោគជ័យ៖

*"តាមគំនិតរបស់ខ្ញុំ គួរតែមានការណែនាំពីស្ថាប័នហិរញ្ញវត្ថុ FIs ស្តីពីការអភិវឌ្ឍន៍អាជីវកម្ម និងការគ្រប់គ្រងសម្រាប់ WEs ដើម្បីធ្វើឱ្យអាជីវកម្មរបស់ពួកគេរីកចម្រើន ដូច្នេះវាងាយស្រួលសម្រាប់ពួកគេក្នុងការទទួលបានប្រាក់ចំណេញ និងសងត្រលប់នូវប្រាក់កម្ចី"* - WE IDI នៅបាត់ដំបង។

*"វាជាការល្អដែលមានការបណ្តុះបណ្តាល ឬសិក្ខាសាលាសម្រាប់សហគ្រិនស្ត្រី WEs ដើម្បីសិក្សាអំពីផែនការហិរញ្ញវត្ថុ ដូចជាការរក្សាកំណត់ត្រាត្រឹមត្រូវលើប្រាក់ចំណូល និងការចំណាយ និងរបៀបបង្កើតផែនការអាជីវកម្ម ព្រោះខ្ញុំនៅតែមិនយល់ច្បាស់អំពីរឿងទាំងនេះ ហើយខ្ញុំជឿថាស្ថាប័នហិរញ្ញវត្ថុ FIs នឹងមិនទុកចិត្តខ្ញុំក្នុងការទទួលបានប្រាក់កម្ចីពីពួកគេទេ" ។* - WE IDI នៅបាត់ដំបង។

មួយផ្សេងទៀតបានចែករំលែកពីរបៀបដែលស្ថាប័នហិរញ្ញវត្ថុ FIs អាចបង្កើតកម្មវិធីណែនាំ ដើម្បីលើកទឹកចិត្តដល់ការរៀនពីគ្នាទៅវិញទៅមកសម្រាប់សហគ្រិនស្ត្រី៖

*"ខ្ញុំចង់ស្នើឱ្យ FIs ផ្តល់ការចែករំលែងពីសហគ្រិនស្ត្រី WEs មុនៗ ដែលទទួលបានប្រាក់កម្ចីជោគជ័យ"* - WE IDI នៅរាជធានីភ្នំពេញ។

ជាចុងក្រោយ យើងបានស្នើថាស្ថាប័នហិរញ្ញវត្ថុ FIs គួរតែមានស្មារតីកាន់តែខ្លាំង ដោយបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការគាំទ្រស្ត្រីមកពីមជ្ឈដ្ឋានផ្សេងៗគ្នា៖

*"ខ្ញុំចង់មានការផ្សាយពាណិជ្ជកម្ម និងការប្រកាសប្រភេទផ្សេងគ្នាទៅកាន់សហគ្រិនស្ត្រី WE និងអ្នកដែលមានអន្តរប្រសព្វ"* - WE IDI នៅបាត់ដំបង។

អនុសាសន៍៖

➔ អង្គការគាំទ្រសហគ្រិន ESOs និងស្ថាប័នហិរញ្ញវត្ថុ FIs គួរតែសហការគ្នាក្នុងកម្មវិធីបណ្តុះបណ្តាល និងបង្វឹកបង្ហាត់ផ្តល់ចំនេះដឹងដល់សហគ្រិនស្ត្រីអំពីការគ្រប់គ្រងហិរញ្ញវត្ថុ ការយល់ដឹងអំពីឥណទាន និងការធ្វើផែនការហិរញ្ញវត្ថុ។

➔ នៅពេលពិចារណាពីអន្តរប្រសព្វ គួរតែមានការពិចារណាលើលទ្ធភាពក្នុងការប្រើប្រាស់អោយកាន់តែច្រើនសម្រាប់សម្ភារៈ និងទីកន្លែង ការប្រើប្រាស់ភាសាសញ្ញា និង/ឬអក្សរស្ទាប និងផ្តល់ឱកាសកាន់តែច្រើនដល់ស្ត្រីសហគ្រិនជាជនជាតិដើមភាគតិច និងជនជាតិភាគតិច MSMEs។

➔ គួរតែមានការយកចិត្តទុកដាក់អោយកាន់តែច្រើនអំពីរបៀបដែលកម្មវិធី ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលត្រូវបានផ្សព្វផ្សាយ ដោយធានាថាមានតំណាងនៃសហគ្រិនស្ត្រី WEs ចម្រុះដែលប្រសើជាងមុន បង្កើតភាពលេចធ្លោរឱ្យកាន់តែច្រើនពីបទពិសោធន៍ និងតម្រូវការរបស់ពួកគេ។

## ជ្រុងទី 2: ធនធាន

ជ្រុងនេះផ្តោតលើរបៀបដែលធនធានដូចជាសំឡេង សេរីភាពពីអំពើហិង្សា និងការទទួលបានឥណទានខ្នាតតូច សេវាសុខភាពសាធារណៈ និងការអប់រំដែលមានឥទ្ធិពលដល់សហគ្រិនស្ត្រី WEs។ ដោយសារការទទួលបានធនធានផ្លូវការដូចជាឥណទានខ្នាតតូចបំផុត ត្រូវបានពិភាក្សាលម្អិតនៅក្នុងផ្នែកទី 3៖ ការរកឃើញ ផ្នែកនេះផ្តោតសំខាន់លើមតិយោបល់។

សហគ្រិនស្ត្រីម្នាក់(WE) បានចែករំលែកពីរបៀបដែលស្ថាប័នហិរញ្ញវត្ថុ FIs អាចផ្សព្វផ្សាយទៅកាន់អតិថិជនដែលមានលក្ខណៈចម្រុះរបស់ពួកគេបានដោយ៖

*"ស្ថាប័នហិរញ្ញវត្ថុFIs គួរតែមានកម្មវិធីតាំងពិព័រណ៍សម្រាប់សហគ្រិនស្ត្រី WEs ដែលមានអន្តរប្រសព្វដើម្បីឱ្យផលិតផលរបស់ពួកគេទទួលបានប្រជាប្រិយភាព និងទទួលបានការគាំទ្រពីសាធារណជន"* - WE IDI នៅភ្នំពេញ។

លើសពីនេះទៀតសហគ្រិនស្ត្រី WEs បានគូសបញ្ជាក់ពីតួនាទីដែលស្ថាប័នហិរញ្ញវត្ថុ FIs អាចដើរតួក្នុងការដោះស្រាយបញ្ហាដែលបង្អាក់ការទទួលបានផលិតផល និងសេវាកម្មហិរញ្ញវត្ថុរបស់សហគ្រិនស្ត្រីអន្តរប្រសព្វ ៖

*"ខ្ញុំចង់ឱ្យស្ថាប័នហិរញ្ញវត្ថុ FIs ផ្តល់អំណាចដល់ស្ត្រីទាំងនេះ"* - WE IDI នៅបាត់ដំបង។

នេះបង្ហាញថាការបង្កើតឱកាសសម្រាប់បុគ្គលដូចជាសហគ្រិនស្ត្រី WE ក្នុងការចែករំលែកសំឡេងរបស់ពួកគេត្រូវបានភ្ជាប់ដោយផ្ទាល់ជាមួយនឹងលទ្ធភាពរបស់ពួកគេក្នុងការទទួលបានធនធានផ្លូវការដូចជាឥណទានខ្នាតតូចបំផុតជាដើម។

អនុសាសន៍៖
➔ ជួយសម្រួលដល់សហគ្រិនស្ត្រី WEs អោយចូលទៅកាន់ទីផ្សារដែលទូលំទូលាយ ជួយផ្សព្វផ្សាយអាជីកម្មរបស់ពួកគេតាមរយៈភាពជាដៃគូ ព្រឹត្តិការណ៍បង្កើតបណ្ដាញទីផ្សារ និងពិព័រណ៍ពាណិជ្ជកម្មផ្សេងៗ។
➔ ជំរុញការតស៊ូមតិ និងកិច្ចពិភាក្សាគោលនយោបាយ ដោយធ្វើការតស៊ូមតិសម្រាប់គោលនយោបាយដែលគាំទ្រសហគ្រិនស្ត្រីWEs ដូចជាអត្រាការប្រាក់ឧបត្ថម្ភធនសម្រាប់ MSMEs ដែលគ្រប់គ្រងដោយស្ត្រី និងពន្ធលើកទឹកចិត្ត។
➔ កែលម្អលទ្ធភាពទទួលបានព័ត៌មានឥណទានដោយសហការជាមួយការិយាល័យឥណទាន ដើម្បីធានាថាសកម្មភាពឥណទានរបស់ WEs ត្រូវបានកត់ត្រាយ៉ាងត្រឹមត្រូវ និងរាយការណ៍បានទាន់ពេលវេលា ដើម្បីជួយពួកគេបង្កើតប្រវត្តិឥណទានដ៏ល្អ។

## ជ្រុងទី 3: បទដ្ឋានក្រៅផ្លូវការ និងការអនុវត្តក្រៅប្រព័ន្ធ

ជ្រុងនេះស្វែងយល់ពីបទដ្ឋានក្រៅផ្លូវការ និងការអនុវត្តការមិនរាប់បញ្ចូល។ ផ្ទុយពីគោលការណ៍ផ្លូវការ និងនីតិវិធីប្រតិបត្តិការស្តង់ដារ ទាំងនេះគឺជាអាកប្បកិរិយា និងអាកប្បកិរិយាក្រៅផ្លូវការដែលអាចមានការរើសអើងដោយចេតនា ឬដោយអចេតនា ដោយដឹងខ្លួន ឬដោយមិនដឹងខ្លួន មានការរើសអើងប្រឆាំងនឹងសហគ្រិនស្ត្រី WEs ជាទូទៅ ឬ សហគ្រិនស្ត្រីអន្តរប្រសព្វ។

ឧទាហរណ៍មួយនៃការរើសអើងក្រៅផ្លូវការ គឺការសន្មត់ ឬការវិនិច្ឆ័យដែលបុគ្គលិកស្ថាប័នហិរញ្ញវត្ថុ អាចធ្វើឡើងលើសហគ្រិនស្ត្រី WEs ដោយសារតែរូបរាងខាងក្រៅរបស់ពួកគេ ដែលអាចបណ្ដាលមកពីភាពក្រីក្រ ពិការភាព ឬអត្តសញ្ញាណយេនឌ័រដែលមិនអាចកំនត់បាន។ សហគ្រិនស្ត្រីម្នាក់បាននិយាយថា:

> *"ស្ថាប័នហិរញ្ញវត្ថុ FIs គួរតែសិក្សាឱ្យបានលម្អិតជាមួយម្ចាស់អាជីវកម្មមុននឹងធ្វើការវិនិច្ឆ័យលើសមត្ថភាពរបស់ពួកគេដោយផ្អែកលើកត្តារូបរាងខាងក្រៅរបស់ពួកគេតែមួយមុខ"* - WE IDI នៅភ្នំពេញ។

សហគ្រិនស្ត្រី WEs ក៏បានចែករំលែកនូវរចនាសម្ព័ន្ធដែលបានចាក់ឫសយ៉ាងជ្រៅក្នុងការគិតពីសមភាពយេនឌ័រ បែបអភិរក្ស ដែលវាបានបង្កើតជាឧបសគ្គដល់សហគ្រិនស្ត្រី WEs ។ សហគ្រិនស្ត្រី WEs បានស្នើឱ្យស្ថាប័នហិរញ្ញវត្ថុ FIs ផ្តល់ការបណ្តុះបណ្តាលអន្តរប្រសព្វ និងការគិតដល់សមភាពយេនឌ័រដល់បុគ្គលិករបស់ពួកគេ ដូច្នេះពួកគេនឹងយល់ប្រសើរជាងមុននៅពួកត្រូវស្វែងយល់ពីតម្រូវការរបស់សហគ្រិនស្ត្រី WEs ។ លើសពីនេះ ចំណុចសំខាន់មួយទៀតដែលសហគ្រិនស្ត្រី WEs បានលើកឡើងគឺត្រូវធានាថាវាពិតមានអន្តរប្រសព្វ ដើម្បីឱ្យពួកគេអាចផ្តល់នូវសេវាកម្ម

ប្រកបដោយវិជ្ជាជីវៈជាមួយសហគ្រិនស្ត្រី WEs ដែលមានពិការភាព។ នេះនឹងអនុញ្ញាតឱ្យសហគ្រិនស្ត្រី WEs ទទួលបានប្រាក់កម្ចីកាន់តែច្រើន។

លើសពីនេះ សហគ្រិនស្ត្រីម្នាក់ទៀតបានចែករំលែកពីរបៀបដែលបទដ្ឋានក្រៅផ្លូវការរារាំងដល់ការអនុវត្តគោលនយោបាយផ្លូវការ៖

*"ស្ថាប័នហិរញ្ញវត្ថុFIs ខ្លួនឯងយល់ពីបទពិសោធន៍អន្តរប្រសព្វរបស់សហគ្រិនស្ត្រី WEs ឧទាហរណ៍បុគ្គលិកកម្រិតខ្ពស់ ឬបុគ្គលិកកម្រិតគ្រប់គ្រង។ ពួកគេថែមទាំងមានគោលនយោបាយទៀតផង។ ទោះយ៉ាងណាក៏ដោយ មានគម្លាតក្នុងការអនុវត្តពីបុគ្គលិក (COs)។ ពួកគេខ្វះការបណ្តុះបណ្តាលលើការស្វែងយល់ និងធ្វើការសន្មត់ថាសហគ្រិនស្ត្រី WEs ដែលមានពិការភាពអាចជាឧបសគ្គសម្រាប់ពួកគេក្នុងការចូលទៅជិត ឬពិបាកក្នុងការស្នើសុំឱ្យសងប្រាក់កម្ចីវិញ»* - WE IDI នៅភ្នំពេញ

អង្គការមួយចំនួនបានធ្វើការជាមួយ MFIs និងធនាគារដើម្បីផ្តល់ការបណ្តុះបណ្តាលលើការរួមបញ្ចូល ខណៈពេលដែលការបង្កើតព្រឹត្តិការណ៍ដើម្បីផ្សព្វផ្សាយនិងបង្ហាញអាជីវកម្ម WWDs មានលទ្ធផលវិជ្ជមាន៖

*"អង្គការរបស់យើងធ្វើការជាមួយមីក្រូហិរញ្ញវត្ថុ MFIs និងធនាគារដើម្បីផ្តល់នូវការបណ្តុះបណ្តាលអំពីការរួមបញ្ចូល និងការយល់ដឹង (គោលនយោបាយ ឯកសារ ការអនុវត្តដើម្បីធ្វើឱ្យព័ត៌មានងាយស្រួលក្នុងការស្វែងរក) និងបង្កើតសៀវភៅណែនាំអំពីការរួមបញ្ចូលក្នុងវិស័យធនាគាដើម្បីចែករំលែកដល់ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ"* - KII ជាមួយស្ថាប័នមួយ។

*"នៅឆ្នាំ 2020 អង្គការរបស់យើងបានបង្កើតទីផ្សារមួយដែលយើងបានអញ្ជើញអ្នកពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល ធនាគារ និងក្រសួងនានាឱ្យចូលរួម និងបង្ហាញពីសមិទ្ធផលអាជីវកម្មរបស់ WWDs និងរបៀបដែលពួកគេធ្វើឱ្យមាននិរន្តរភាព។ យើងក៏មានគោលបំណងបង្កើនការយល់ដឹង និងភាពជាការពិតរវាងអ្នកផ្តល់កម្ចី និង WWDs»* - KII ជាមួយស្ថាប័នមួយ។

ជាមួយនឹងគំនិតផ្តួចផ្តើមដែលដោះស្រាយវិសមភាពយេនឌ័រ និងការរួមបញ្ចូល មានការប្រើប្រាស់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ នឹងមានកាន់តែច្រើន និងបើកចំហកាន់តែទូលាយសម្រាប់សហគ្រិនស្ត្រី WE ដែលអាចជះឥទ្ធិពលវិជ្ជមានដល់ពួកគេ និងប្រទេសកម្ពុជាទាំងមូល។

អនុសាសន៍៖

➔ ដោះស្រាយការរើសអើងក្រៅផ្លូវការជាការអនុវត្ត និងជារចនាសម្ព័ន្ធនៅក្នុងស្ថាប័នហិរញ្ញវត្ថុ FIs តាមរយៈការបណ្តុះបណ្តាលបែបចម្រុះភាព សមធម៌ និងបរិយាបន្ន (DEI) ដើម្បីបង្កើនការយល់ដឹងអំពីវិសមភាពយេនឌ័រ ការរើភាគពីអំនាច អន្តរប្រសព្វ និងសារៈសំខាន់នៃការរួមបញ្ចូលនៅក្នុងសេវាកម្មហិរញ្ញវត្ថុ។

➔ ចូលរួមជាមួយសហគមន៍ដើម្បីដោះស្រាយការយល់ឃើញអំពីសមត្ថភាពរបស់សហគ្រិនស្ត្រី WE ក្នុងការគ្រប់គ្រងប្រាក់កម្ចី។ នេះអាចរួមបញ្ចូលការចែករំលែករឿងរ៉ាវជោគជ័យ និងយុទ្ធនាការដែលសង្កត់ធ្ងន់លើអត្ថប្រយោជន៍សេដ្ឋកិច្ចនៃការផ្តល់សិទ្ធិអំណាចដល់សហគ្រិនស្ត្រី WEs ជាមួយនឹងអន្តរប្រសព្វ។

➔ បង្កើនភាពជាដៃគូជាមួយអង្គការដែលមិនរកប្រាក់កម្រៃដែលផ្តោតលើសមភាពយេនឌ័រ ដើម្បីស្វែងយល់កាន់តែច្បាស់ពីតម្រូវការរបស់ សហគ្រិនស្ត្រី WEs ដើម្បីបង្កើតផលិតផល និងសេវាកម្មហិរញ្ញវត្ថុសមស្របសម្រាប់ពួកគេ។

## ជ្រុងទី 4: ច្បាប់ និងគោលការណ៍ផ្លូវការ

ជ្រុងនេះគ្របដណ្តប់លើច្បាប់និងបទប្បញ្ញត្តិផ្លូវការ គោលនយោបាយ និងនីតិវិធីប្រតិបត្តិការស្តង់ដារ ដែលរើសអើងសហគ្រិនស្ត្រី WEs ជាក្រុម ឬជាក្រុមអន្តរប្រសព្វវង។

ការផ្តល់យោបល់មួយពី សហគ្រិនស្ត្រីWEs គឺថាស្ថាប័នហិរញ្ញវត្ថុ FIs មិនគួរអនុវត្តវិធីសាស្ត្រ "ទំហំមួយត្រូវទាំងអស់" ចំពោះសហគ្រិនស្ត្រី WEs ជាមួយនឹងផលិតផល និងសេវាកម្មហិរញ្ញវត្ថុស្តង់ដារតែមួយ ប៉ុន្តែត្រូវបង្កើតផលិតផលនិងសេវាកម្មផ្សេងៗគ្នាសម្រាប់ប្រភេទអាជីវកម្ម និងសហគ្រិនដែលមានលក្ខណៈអន្តរប្រសព្វ ព្រោះថាវានឹងមានភាពសុក្រិត្យជាង។ ការអនុវត្តវិធីសាស្ត្របែបនេះនឹងតម្រូវអោយទម្រង់ស្តង់ដារច្រើន ឬវិធីសាស្ត្រនៃការដាក់ពាក្យស្នើរកម្ចីច្រើនរបៀបតម្រូវសម្រាប់អាជីវកម្មនីមួយៗ ហើយតម្រូវការនៃដំណើរការពិគ្រោះយោបល់មួយទល់នឹងមួយបន្ថែមទៀត ប្រហែលជាមានចំណុចជាច្រើនទៀតដែលត្រូវកែតម្រូវ។ យើងទទួលស្គាល់ថាថ្លៃប្រតិបត្តិការសម្រាប់ស្ថាប័នហិរញ្ញវត្ថុ FIs នឹងត្រូវកើនឡើង ដោយឡែកអត្រាការប្រាក់ខ្ពស់គឺជាកង្វល់សម្រាប់សហគ្រិនស្ត្រី WEs រួចទៅហើយ ដូច្នេះដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតនឹងត្រូវការជាចាំបាច់ដើម្បីផ្តល់នូវកម្រិតនៃសេវាកម្មនេះក្នុងការចំណាយដែលអាចគ្រប់គ្រងបាន។

សហគ្រិនស្ត្រី WEs បានចង្អុលបង្ហាញថា ដោយសារតែអ្នកខ្លះទទួលបានតិចតួចឬ មិនបានទទួលការអប់រំផ្លូវការ ពួកគេពិបាកក្នុងការបំពេញតម្រូវការ និង "ខ្សែអាត់ក្រហម" នៃដំណើរការស្នើសុំប្រាក់កម្ចី និងលក្ខខ័ណ្ឌគោលនយោបាយរបស់ធនាគា ដែលនឹងត្រូវលេចឡើងក្រោយពេលពួកគាត់ទទួលបានកម្ចីជាស្ថាពរ។ ឧទាហរណ៍៖ ដើម្បីវិភាគ និងសិក្សាលើអាជីវកម្មដើម្បីមើលថាតើអាជីវកម្មនោះមានលទ្ធភាពសងប្រាក់កម្ចីបានដោយមិនចាំបាច់មានវត្ថុបញ្ចាំ; ឬស្វែងរកដំណោះស្រាយ ឬឯកសារជំនួសមកជំនួសឯកសារដែលស្ថិតក្នុងតម្រូវការរបស់ធនាគា នោះនឹងពិបាកសម្រាប់សហគ្រិនស្ត្រី WEs ក្នុងការទទួលបានកម្ចី។ នេះជាករណីពិសេសសម្រាប់សហគ្រិនស្ត្រី WEs ដែលនៅលីវ និង

សហគ្រិនស្ត្រីWEsជាមេម៉ាយ។ មានសំណើរដែលបានស្នើថាស្ថាប័នហិរញ្ញវត្ថុ FIs គួរតែផ្តល់ឱ្យសហគ្រិនស្ត្រីនូវឱកាសស្មើៗគ្នាក្នុងការដាក់ពាក្យ និងទទួលបានប្រាក់កម្ចី ប្រសិនបើពួកគេមានសមត្ថភាពសងប្រាក់កម្ចី ដោយគ្មានវត្ថុបញ្ចាំ ឬអ្នកធានា ប៉ុន្តែដើម្បីវិភាគអាជីវកម្ម និងសមត្ថភាពរបស់សហគ្រិនស្ត្រី WEs ។ នេះអាចរួមបញ្ចូលលក្ខខណ្ឌកម្ចីដែលអាចបត់បែនបានបន្ថែមទៀតដែលដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងវត្ថុបញ្ចាំ និងអត្រាការប្រាក់៖

*"ខ្ញុំចង់ស្នើឱ្យស្ថាប័នហិរញ្ញវត្ថុ FIs គិតពីខ្ញុំ ដែលមិនមានលទ្ធភាពសងប្រាក់កម្ចីដោយកែសម្រួលបញ្ជីបង់ប្រាក់ដែលមានរយៈពេលវែងជាងមុន និងការទូទាត់តិចជាងមុន"*- WE IDI នៅបាត់ដំបង

*"ខ្ញុំចង់ឱ្យស្ថាប័នហិរញ្ញវត្ថុ FIs គិតម្តងទៀតអំពីវត្ថុបញ្ចាំ ព្រោះនេះជាបញ្ហាធំដែលប៉ះពាល់ដល់ឱកាសទទួលបានកម្ចីរបស់សហគ្រិនស្ត្រី WEs ដែលមានអាជីវកម្មខ្នាតតូច"* - WE IDI នៅភ្នំពេញ

នៅពេលក្រឡេកមើលអត្រាការប្រាក់សហគ្រិនស្ត្រី WEs ជាច្រើនបានស្នើសុំការពិចារណាអោយមានករណីពិសេសសម្រាប់អ្នកដែលមកពីមជ្ឈដ្ឋានផ្សេងៗគ្នា ដើម្បីធ្វើឱ្យមានភាពងាយស្រួលជាងមុនក្នុងការទទួលបានហិរញ្ញវត្ថុ៖

*"មិត្តរបស់ខ្ញុំគឺជាស្ត្រីមេម៉ាយ។ ស្ថាប័នហិរញ្ញវត្ថុFIs គួរតែផ្តល់ឱ្យនាងនូវអត្រាការប្រាក់ទាបដើម្បីឱ្យនាងកាន់តែមានភាពងាយស្រួលក្នុងការសងត្រឡប់មកវិញនូវប្រាក់កម្ចី និងការពារនាងនៅពេលដែលអាជីវកម្មរបស់នាងដំណើរការមិនល្អជាមួយនឹងប្រាក់ចំណូលទាប។ ខ្ញុំចង់ស្នើឱ្យស្ថាប័នហិរញ្ញវត្ថុ FIs សិក្សាអត្រាការប្រាក់ត្រឹមតែ 4-5% សម្រាប់ WEs ដើម្បីគាំទ្រពួកគេក្នុងការដំណើរការអាជីវកម្មរបស់ពួកគេ"* - WE IDI នៅភ្នំពេញ

*"យើងចង់បានអត្រាការប្រាក់ទាបសម្រាប់អ្នកដែលមានអន្តរប្រសព្វដូចពួកយើង។ ស្ថាប័នហិរញ្ញវត្ថុFIs គួរតែមានការផ្សព្វផ្សាយសម្រាប់សហគ្រិន WEs និងផ្តល់សេវាកម្មលម្អិតសម្រាប់ពួកយើង ទោះបីជាយើងជាស្ត្រីមេម៉ាយ រស់នៅជាមួយភាពក្រីក្រ ឬនៅលីវក៏ដោយ"* - WE FGD នៅបាត់ដំបង។

យើងទទួលស្គាល់ថាវាមិនងាយស្រួលទេសម្រាប់ស្ថាប័នហិរញ្ញវត្ថុFIs ក្នុងការកាត់បន្ថយអត្រាការប្រាក់របស់ពួកគេសម្រាប់អតិថិជនទាំងអស់ ជាពិសេសសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលប្រតិបត្តិការនៅតំបន់ជនបទ។ យើងយល់ថាមានភាពតានតឹងរវាងសហគ្រិនស្ត្រី WEs ដែលចង់បានអត្រាការប្រាក់ទាប និងគំរូអាជីវកម្មរបស់ស្ថាប័នហិរញ្ញវត្ថុ FIs ដែលអាស្រ័យលើស្ថានភាពសេដ្ឋកិច្ច ។

**អនុសាសន៍៖**

- ➔ **ផ្តល់ជូននូវភាពបត់បែនបានលើតម្រូវការទ្រព្យបញ្ចាំ និងលក្ខខណ្ឌនៃការសងត្រឡប់ ប្រសិនបើអាចធ្វើទៅបាន។**
- ➔ **រកវិធីសាស្ត្រផ្សេងៗក្នុងការស្វែងយល់ពីអាជីវកម្មដើម្បីកំណត់ថាតើពួកគេអាចសងប្រាក់កម្ចីដោយគ្មានទ្រព្យបញ្ចាំ។**
- ➔ **ជួយសម្រួលដល់ការបង្កើតកម្មវិធី និងផលិតផលសន្សំ ដែលអាចបម្រើជាឯកសារយោងនៃប្រវត្តិឥណទានដ៏ល្អ។**
- ➔ **កំណត់គោលដៅសម្រាប់ការផ្តល់ប្រាក់កម្ចីដល់អាជីវកម្មដែលគ្រប់គ្រងដោយស្ត្រី និងតាមដានវឌ្ឍនភាពដោយផ្តោតលើអន្តរប្រសព្វ។**

## V. សេចក្តីសន្និដ្ឋាន

ការសិក្សានេះបានពិនិត្យលើបញ្ហាប្រឈមជាលក្ខណៈអន្តរប្រសព្វដែលប៉ះពាល់ដល់សហគ្រិនស្ត្រីនៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ក្នុងការទទួលបានហិរញ្ញវត្ថុ និងការវិនិយោគជាបន្តបន្ទាប់។

ដោយប្រើវិធីសាស្ត្រស្រាវជ្រាវបែបហ្វេមីនីស (Feminist Action Research) យើងបានចែករំលែកមតិយោបល់ផ្ទាល់ខ្លួនរបស់សហគ្រិនស្ត្រី WEs ចម្រុះ និងអ្នកស្រាវជ្រាវស្ត្រីដែលបានចូលរួមជាមួយពួកគេ ដើម្បីបង្កើតការយល់ដឹងពិសេសពីអតិថិជននៃផលិតផល និងសេវាកម្មហិរញ្ញវត្ថុ។ ដូច្នេះ ការស្រាវជ្រាវនេះអាចរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយវិសមភាពយេនឌ័រ ដោយកំណត់អត្តសញ្ញាណឧបសគ្គពិសេសដែលស្ត្រីដែលមានចម្រុះភាពនៃបទពិសោធន៍ និងប្រវត្តិរូបផ្សេងៗគ្នាបានប្រឈមមុខក្នុងការទទួលបានផលិតផលហិរញ្ញវត្ថុ សេវាកម្ម និងការវិនិយោគជាបន្តបន្ទាប់។ ការយល់ដឹងពីការស្រាវជ្រាវនេះក៏អាចជាព័ត៌មានដល់អ្នកបង្កើតគោលនយោបាយ ស្ថាប័នហិរញ្ញវត្ថុ និងអង្គការអភិវឌ្ឍន៍នានា ដើម្បីរៀបចំផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលរួមបញ្ចូលបន្ថែមទៀត ស្របតាមតម្រូវការរបស់ WEs ។ លើសពីនេះទៀត ការសិក្សានេះអាចជំរុញការអភិវឌ្ឍកម្មវិធីគាំទ្រឯកទេស គំនិតផ្តួចផ្តើមក្នុងការកសាងជំនាញ និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិក្នុងការបង្កើតទិដ្ឋភាពធុរកិច្ចដោយយុត្តិធម៌ ដែលផ្តល់សិទ្ធិអំណាចដល់ WEs ក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។ ទោះជាយ៉ាងណាក៏ដោយ វិសាលភាពនៃការសិក្សានេះមានដែនកំណត់។ ការសិក្សាមិនមានឱកាសក្នុងការទទួលបានការជួបសម្ភាសន៍រាប់បញ្ចូលសំឡេងរបស់ស្ថាប័នហិរញ្ញវត្ថុ FIs និងភ្នាក់ងារនិយតកម្មទេ។ ដូច្នេះហើយ យើងលើកទឹកចិត្តឱ្យមានការស្រាវជ្រាវនាពេលអនាគតលើផ្នែកផ្គត់ផ្គង់នៃផលិតផលនិងសេវាកម្មហិរញ្ញវត្ថុ និងបរិយាកាសអំណោយផលសម្រាប់សហគ្រិនស្ត្រី WEs និងស្ថាប័នហិរញ្ញវត្ថុ FIs ដោយមានគោលបំណងកំណត់គោលនយោបាយ ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ

ដែលរួមបញ្ចូលសមភាពយេនឌ័រ ដែលអាចបង្កើនលទ្ធភាពទទួលបាន ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុបែប បរិយាបន្ន។

ទោះបីជាបញ្ហាប្រឈមនៃការទទួលបានព័ត៌មាន ដំណើរការកម្មវិធីស្មុគស្មាញ តម្រូវការវត្ថុបញ្ចាំ និងអត្រាការប្រាក់ខ្ពស់ត្រូវបានគេរកឃើញថាជាឧបសគ្គដែលបន្តមានឥទ្ធិពលលើសហគ្រិនស្ត្រី ភាពស្មុគស្មាញបានកើនឡើងនៅពេលយើងស្វែងយល់បន្ថែមពីការឆ្លុះបញ្ចាំងនៃអន្តរប្រសព្វ។ ដោយប្រើក្របខ័ណ្ឌយេនឌ័រនៅកន្លែងការងារដើម្បីស្វែងយល់ពីសក្តានុពលផ្លូវការ ក្រៅផ្លូវការ លក្ខណៈបុគ្គល និងជាប្រព័ន្ធក្នុងការទទួលបានហិរញ្ញវត្ថុ ការសិក្សានេះបានចែករំលែកបទពិសោធន៍របស់សហគ្រិនស្ត្រី WEs ដែលមានពិការភាព អនក្ខរកម្ម ទំនោរផ្លូវភេទនិងការបង្ហាញអត្តសញ្ញាណយេនឌ័រចម្រុះភាព សមាសភាពគ្រួសារ "មិនតាមប្រពៃណី" និងអ្នកដែលគោរពសាសនាផ្សេងៗគ្នា។ គួរបញ្ជាក់ផងដែលថា ដើម្បីទទួលបាននូវការវិនិយោគជាបន្តបន្ទាប់ បញ្ហាប្រឈមក្នុងការទទួលបានដើមទុនពីប្រភពផ្សេងៗគ្នាគួរតែត្រូវបានសង្កត់ធ្ងន់ដើម្បីស្វែងរកដំណោះស្រាយ។ ដោយពិចារណាលើសក្តានុពលទាំងនេះ យើងបានចែករំលែកនូវអនុសាសន៍ដែលបានមកពីបទពិសោធន៍ និងទស្សនៈរបស់សហគ្រិនស្ត្រី WEs ដោយសង្ឃឹមថាភាគីពាក់ព័ន្ធអាចប្រើប្រាស់ការយល់ដឹងទាំងនេះ ដើម្បីគាំទ្រដល់លទ្ធភាពទទួលបានហិរញ្ញវត្ថុកាន់តែច្រើនសម្រាប់សហគ្រិនស្ត្រី WEs នៅព្រះរាជាណាចក្រកម្ពុជា។

យើងសង្ឃឹមថាភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធអេកូឡូស៊ីនៃសហគ្រិនភាពនឹងរួមដៃសហការគ្នា និងធ្វើការរួមគ្នាសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុដែលមានបរិយាបន្ន អោយមានកាន់តែច្រើន ដែលជាប្រព័ន្ធមួយដែលពង្រីកសក្តានុពលរបស់សហគ្រិនស្ត្រី WE ដែលផ្តល់អត្ថប្រយោជន៍សម្រាប់ខ្លួនគេ ក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ និងបង្កើតការអភិវឌ្ឍន៍សម្រាប់អនាគតសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។

# ឯកសារយោង


Asian Development Bank (ADB) (2015). ADB support for gender and development: Country portfolio assessment, Cambodia. https://www.adb.org/sites/default/files/evaluation-document/181135/files/country-portfolio-assessment-cambodia.pdf

ADB (2018). An Overview of Islamic Banking and Finance in Asia. https://www.adb.org/sites/default/files/publication/436751/adbi-wp853.pdf

Ackerman, C. E. (2018). What is self-concept theory? A psychologist explains. Self-awareness. https://positivepsychology.com/self-concept/#what-self-concept

Allen, I. E., Elam, A., & Langowitz, N. (2019). Gendered Pathways: How Social Dynamics and Structural Influences Shape the Financing of Women-Owned Ventures. Academy of Management Perspectives, 33(4), 445-470.

Anand, S. (2016). Case Study 2: How Working in a Collective Boosts Self-Esteem and Choice-Making Propensity in Women. In: Kumar, P. (eds) Indian Women as Entrepreneurs. Palgrave Macmillan, London. https://doi.org/10.1057/978-1-137-60259-6_10

Armendariz, B., & Morduch, J. (2010). The Economics of Microfinance. MIT Press.

Banerjee, A., Duflo, E., Glennerster, R., & Kinnan, C. (2015). The Miracle of Microfinance? Evidence from a Randomised Evaluation. American Economic Journal: Applied Economics, 7(1), 22-53.

Besheer, M. (2021). Women must have autonomy over their bodies, Un says. VOA. https://www.voanews.com/a/science-health_women-must-have-autonomy-over-their-bodies-un-says/6204553.html

Bateman, M. (2010). Why Doesn't Microfinance Work? The Destructive Rise of Local Neoliberalism. Zed Books.

Brush, C. G. (1992). Research on Women Business Owners: Past Trends, a New Perspective, and Future Directions. Entrepreneurship: Theory and Practice, 16(4), 5-30.

Cambodia Indigenous Peoples Organization (CIPO). https://cipocambodia.org/our-work/developing-indigenous-peoples-center/#1585208858312-76224c71-df89

Collins, P. H. (2015). Intersectionality's Definitional Dilemmas. Annual Review of Sociology, 41, 1-20.

Coleman, S. (2007). Constraints Faced by Women Small Business Owners: Evidence from the Data. Journal of Developmental Entrepreneurship, 12(4), 437-457.

Doneys, P., Doane, D. L., & Norm, S. (2020). Seeing empowerment as relational: lessons from women participating in development projects in Cambodia. Development in Practice, 30(2), 268–280. https://doi.org/10.1080/09614524.2019.1678570

Duflo, E. (2012). Women's Empowerment and Economic Development. Journal of Economic Literature, 50(4), 1051-1079.

Ellen, R. (2013). Girls rule in new draft of Moral Code. Phnom Penh Post. https://www.phnompenhpost.com/7days/girls-rule-new-draft-moral-code

Equitable Cambodia & Licadho. (2023). *Debt Threats: A Quantitative Study of Micro Loan Borrowers in Cambodia's Kampong Speu Province.* https://equitablecambodia.org/website/data/report/2023/Debt%20Threats_MFI_Report_2023_EN.pdf

Gender at Work Framework. https://genderatwork.org/analytical-framework/

Goetz, A. M., & Sen Gupta, R. (1996). Who Takes the Credit? Gender, Power, and Control over Loan Use in Rural Credit Programs in Bangladesh. World Development, 24(1), 45-63.

Hanson, C. (2020). RAPID RESEARCH REPORT SEPTEMBER 2020 PHASE 2: "IMPACT OF COVID-19 ON WOMEN ENTREPRENEURS WITH DISABILITIES IN CAMBODIA". Agile Development Group. DOI: 10.13140/RG.2.2.10332.31364

HBS Law (2023) Islamic Finance in Cambodia. https://www.hbslaw.asia/images/Related-Publications/2023/Insight-Islamic-Finance-in-Cambodia.pdf

Heng, M. (2022). Cambodia's gender policy: An analysis of women and girls' education strategies under the Neary Rattanak IV Strategic Plan (2014-2018). Cambodian Journal of Educational Research (2022). Vol. 2, No. 1, pp. 37–61.

Higgs, J. 2022 July. Fighting for women's rights and autonomy in Cambodia, Independent Australia. https://independentaustralia.net/life/life-display/fighting-for-womens-rights-and-autonomy-in-cambodia,16590

Hossain, M. (2010). Microfinance and its Discontents: Women in Debt in Bangladesh. University of Minnesota Press.

Hulme, D., & Mosley, P. (1996). Finance Against Poverty: Volume 1 (1st ed.). Routledge. https://doi.org/10.4324/9780203980132

Impact Hub (2024) Unlocking accessible support for Indigenous Entrepreneurs. https://impacthub.net/wp-content/uploads/2024/04/EN_TOOLKIT-FOR-INCLUSIVE-AND-RELEVANT-BUSINESS-SUPPORT-FOR-INDIGENOUS-ENTREPRENEURS.pdf

International Finance Corporation. (2019). Annual Report 2019: "Investing for Impact" https://www.ifc.org/content/dam/ifc/doc/mgrt/ifc-ar19-full-report.pdf

Kabeer, N. (1999). Resources, Agency, Achievements: Reflections on the Measurement of Women's Empowerment. Development and Change, 30(3), 435–464. https://doi.org/10.1111/1467-7660.00125

Kabeer, N. (2005). Gender equality and women's empowerment: A critical analysis of the third Millennium Development Goal 1. Gender & Development, 13(1), 13-24.

Kim, A. (2022). Economic Freedom Is Key to Empowering Women With More, Better Opportunities. ContentEngine LLC, a Florida limited liability company.

Klahaan. (2020). Exploring the links between "women's economic, social and cultural rights" and "violations of land and housing rights" in Cambodia. Klahaan, United Nations Human Rights Office of The High Commissioner, Cambodia. https://cambodia.ohchr.org/sites/default/files/ESC%20rights%20and%20land%20rights%20violations%20OHCHR%20Klahaan%202020-compressed.pdf

Komijani, Akbar & Taghizadeh-Hesary, Farhad. (2019). An Overview of Islamic Banking and Finance in Asia. (PDF) AN OVERVIEW OF ISLAMIC BANKING AND FINANCE IN ASIA (researchgate.net)

Kong, Y. (2018). "A wave of LGBTI acceptance in Cambodia". Micro Rainbow International Foundation. https://mrifoundation.global/a-wave-of-lgbti-acceptance-in-cambodia/

Kumar, Payal. (Ed.). (2016). Indian Women as Entrepreneurs An Exploration of Self-Identity (1st ed. 2016.). Palgrave Macmillan UK. https://doi.org/10.1057/978-1-137-60259-6

Marlow, S., & McAdam, M. (2013). Gender and Entrepreneurial Capital: Implications for Firm Performance. International Journal of Gender and Entrepreneurship, 5(3), 234-256.

Mayoux, L. (1999). Questioning Virtuous Spirals: Micro-Finance and Women's Empowerment in Africa. Journal of International Development, 11(7), 957-984.

Mayoux, L. (2002). Microfinance and the Empowerment of Women: A Review of the Key Issues. Social Finance Unit, Department of Sociology, Open University.

Meyerson, D. E., & Fletcher, J. K. (2000). A Modest Manifesto for Shattering the Glass Ceiling. Harvard Business Review, 78(1), 126-136.

Montgomery, R., Bhattacharya, D., & Hulme, D. (1996). Credit for the Poor in Bangladesh: The BRAC Rural Development Programme and the Government Thana Resource Development and Employment Programme. International Journal of Urban and Regional Research, 20(2), 274-289.

Morrison, A., Rimmington, M., & Williams, C. (2011). Gender as a Destination: Gendered Routes and Pathways in Women's Entrepreneurship. International Small Business Journal, 29(4), 303-319.

Moser, C. O. N. (1998). The Asset Vulnerability Framework: Reassessing Urban Poverty Reduction Strategies. World Development, 26(1), 1-19.

National Bank of Cambodia (NBC). (2019) National Financial Inclusion Strategy 2019-2025. https://www.nbc.gov.kh/english/publications/blueprints.php

National Bank of Cambodia (NBC). (2020) 2020 Annual Report. https://www.nbc.gov.kh/english/publications/annual_reports.php

National Bank of Cambodia (NBC). (2022) Data on MFI Sector. https://www.nbc.gov.kh/english/economic_research/mfis_reports.php

People in Need and Agile Development Group (2023). Guide on Inclusive Technical and Vocational Education and Training (TVET) for People with Disabilities. https://cambodia.peopleinneed.net/media/publications/2177/file/guide-on-inclusive-tvet-for-people-with-disabilities.pdf

Obiagu, A. N. (2023). Do Women's Education and Economic Empowerment Reduce Gender-based Violence in Nigeria? Journal of International Women's Studies, 25(4), COV12.

Orser, B., Riding, A., & Manley, K. (2011). Women Entrepreneurs and Financial Capital. Entrepreneurship: Theory and Practice, 35(3), 543-565.

Pitt, M. M., & Khandker, S. R. (1998). The Impact of Group-Based Credit Programs on Poor Households in Bangladesh: Does the Gender of Participants Matter? Journal of Political Economy, 106(5), 958-996.

Rashid, S., & Elder, L. (2009). Understanding and Addressing Women's Needs in Microfinance: The Case of BRAC in Bangladesh. Gender & Development, 17(3), 361-376.

Rocca, S. (2018). "LGBTI micro-finance". Micro Rainbow International Foundation. https://mrifoundation.global/lgbti-micro-finance/

Sarasvathy, S. D. (2001). Causation and Effectuation: Toward a Theoretical Shift from Economic Inevitability to Entrepreneurial Contingency. Academy of Management Review, 26(2), 243-263.

Support Her Enterprise Co., Ltd (2022). Policy Brief Challenges of Women-owned MSMEs in Accessing Finance.

Sriram, M. S. (2014). Financial Inclusion for Women in Southeast Asia. Routledge.

Steele, J. (2022). "WHAT TYPES OF DISCRIMINATION DO WOMEN FACE IN YOUR SUPPLY CHAINS? HERE'S HOW TO GET THE DATA YOU NEED TO FIND OUT". Oxfam. https://views-voices.oxfam.org.uk/2022/08/discrimination-women-supply-chains/

Swisscontact. (2019). Connecting the Phnom Penh Entrepreneurial Ecosystem. https://www.swisscontact.org/_Resources/Persistent/5/4/7/c/547c9a21e2021496bf911046ad662a883505238e/Connecting%20the%20Phnom%20Penh%20Entrepreneurial%20Ecosystem.pdf

Swisscontact and Sasakawa Peace Foundation (2024). Gender Lens Investing Landscape Study in Cambodia. https://www.swisscontact.org/en/news/gender-lens-investing-gli-landscaping-study-consultative-workshop-sheds-light-on-challenges-and-opportunities-in-cambodia

UN Women Cambodia. n.d. UN Women Cambodia. UN Women Asia and the Pacific. https://asiapacific.unwomen.org/en/countries/cambodia

World Economic Forum. (2023). "Global Gender Gap Report 2023". World Economic Forum. ISBN-13: 978-2-940631-97-1. https://www.weforum.org/publications/global-gender-gap-report-2023/in-full/gender-gaps-in-the-workforce/

The Global Economy. (2023). Female labor force participation - Country rankings https://www.theglobaleconomy.com/rankings/female_labor_force_participation/South-East-Asia/

The World Bank Group. (2014). Expanding Women's Access to Financial Services. https://www.worldbank.org/en/results/2013/04/01/banking-on-women-extending-womens-access-to-financial-services

The World Bank Group. (2022). "Female labor force participation". https://genderdata.worldbank.org/en/data-stories/flfp-data-story

# ឧបសម្ព័ន្ធ

Table of Data Analyse Inteview

SHE_Final_Draft_Policy_Brief_on_Challen